# ខ និង លក្ខខណ្ឌធានារ៉ាប់រង

# ឈ្មោះផលិតផល: "សេចក្តីស្រលាញ់យូរអង្វែង"

# ផលិតផលទី៩ របស់ក្រុមហ៊ុន ហ្គ្រេន ឆាយណា ឡាយហ្វ៍ អ៊ិនសួរេន ម.ក

## ប្រការ ១.- សមាសភាពនៃកិច្ចសន្យាធានារ៉ាប់រង

កិច្ចសន្យាធានារ៉ាប់រង “សេចក្តីស្រលាញ់យូរអង្វែង” (តទៅហៅថា “កិច្ចសន្យាធានារ៉ាប់រង”) បង្កើតឡើងដោយវិញ្ញាបនបត្រធានារ៉ាប់រង ខ និងលក្ខខណ្ឌធានារ៉ាប់រង ពាក្យស្នើសុំធានារ៉ាប់រង (រួមបញ្ចូល “លិខិតបញ្ជាក់ការស្នើសុំធានារ៉ាប់រងតាមរយៈអេឡិចត្រូនិច”)របាយការណ៍ស្តីពីស្ថានភាពសុខភាព សៀវភៅផែនការធានារ៉ាប់រង និងឯកសារផ្សេងទៀតដែលទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រងនេះ។

## ប្រការ ២.- លក្ខខណ្ឌផ្សេងៗដើម្បីដាក់ពាក្យស្នើសុំ

រាល់បុគ្គលដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង មិនមានជំងឺសតិអារម្មណ៍ ព្រមទាំងមានលទ្ធភាពបង់នូវបុព្វលាភក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ នឹងអាចក្លាយជាអ្នកស្នើសុំធានារ៉ាប់រង។

អ្នកស្នើសុំធានារ៉ាប់រងអាចដាក់ពាក្យស្នើសុំសម្រាប់ខ្លួនឯង សមាជិកគ្រួសាររបស់គាត់ និងបុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ពាក់ព័ន្ធ (តទៅហៅថា “អ្នកត្រូវបានធានារ៉ាប់រង”)។ នៅពេលដាក់ពាក្យស្នើសុំ អ្នកត្រូវបានធានារ៉ាប់រងត្រូវសមស្របទៅតាមលក្ខខណ្ឌដូចខាងក្រោម÷

១. ត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង រហូតដល់អាយុ ៥៥ឆ្នាំ

២. មានសុខភាពល្អ និងមិនមានជំងឺសតិអារម្មណ៍

៣. ការងាររបស់អ្នកត្រូវបានធានារ៉ាប់រងមិនមែនជាការងារដែលមានហានិភ័យខ្ពស់។

## ប្រការ ៣.- ការបង្កើតចូលជាធរមាន និងកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រង

នៅពេលអ្នកស្នើសុំធានារ៉ាប់រងដាក់ពាក្យស្នើសុំ និងបានបំពេញបែបបទស្នើសុំធានារ៉ាប់រង ហើយក្រោយពេលក្រុមហ៊ុនយល់ព្រមធានា និងបានផ្តល់ដំណឹងដល់អ្នកស្នើសុំឲ្យបង់បុព្វលាភ កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបានបង្កើត។

ក្រោយពេលកិច្ចសន្យាធានារ៉ាប់រងត្រូវបានបង្កើត បន្ទាប់ពីអ្នកស្នើសុំធានារ៉ាប់រងបានបង់បុព្វលាភធានារ៉ាប់រងទាំងអស់ កិច្ចសន្យាធានារ៉ាប់រងនឹងមានអនុភាព ហើយកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបានបញ្ជាក់ច្បាស់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ នៅពេលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាព ក្រុមហ៊ុននឹងចេញបណ្ណសន្យារ៉ាប់រងជូនអ្នកស្នើសុំធានារ៉ាប់រងភ្លាម។

**ប្រការ ៤.- រយៈពេលធានារ៉ាប់រង**

រយៈពេលធានារ៉ាប់រងនឹងចាប់ផ្តើមគិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ រហូតដល់ខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៨០ឆ្នាំ។

**ប្រការ ៥.- រយៈពេលសម្រេចចិត្ត និងរយៈពេលរង់ចាំ**

១. អ្នកស្នើសុំធានារ៉ាប់រងមានរយៈពេល ២១ថ្ងៃដើម្បីសម្រេចចិត្ត គិតចាប់ពីថ្ងៃបន្ទាប់ដែលអ្នកស្នើសុំធានារ៉ាប់រងចុះហត្ថលេខាទទួលកិច្ចសន្យាធានារ៉ាប់រងនេះ។ ក្នុងអំឡុងពេលសម្រេចចិត្ត ២១ថ្ងៃនេះ អ្នកស្នើសុំអាចស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះបាន។ កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ គិតចាប់ពីពេលដែលក្រុមហ៊ុនទទួលបានពាក្យស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះ ហើយក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងទៀតឡើយ ស្របពេលនោះដែរ ក្រុមហ៊ុននឹងផ្តល់ត្រឡប់នូវបុព្វលាភទាំងអស់ដែលបានបង់ (ដោយគ្មានការប្រាក់) ជូនអ្នកស្នើសុំធានារ៉ាប់រងវិញ ប៉ុន្តែអ្នកស្នើសុំធានារ៉ាប់រងត្រូវបង់ប្រាក់ចំនួន ១០ដុល្លារសហរដ្ឋអាមេរិកមកឲ្យក្រុមហ៊ុនសម្រាប់ថ្លៃសេវាកម្ម។

២. កិច្ចសន្យាធានារ៉ាប់រងនេះបានកំណត់នូវរយៈពេលរង់ចាំចំនួន ៩០ថ្ងៃ។ ក្នុងរយៈពេលរង់ចាំនេះ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងកើតមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងដោយសារតែជំងឺ ក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ។ ចំនួនថ្ងៃនៃរយៈពេលរង់ចាំនឹងត្រូវបានគណនាគិតចាប់ពីថ្ងៃដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាព ឬថ្ងៃបន្តអនុភាពរបស់កិច្ចសន្យាធានារ៉ាប់រងឡើងវិញ។

**ប្រការ ៦.- ទឹកប្រាក់ត្រូវបានធានា**

អ្នកស្នើសុំធានារ៉ាប់រង និងក្រុមហ៊ុនអាចចរចាដើម្បីកំណត់នូវទឹកប្រាក់ត្រូវបានធានា ប៉ុន្តែទឹកប្រាក់ត្រូវបានធានាមិនអាចកំណត់ទាបជាង ១០.០០០(មួយម៉ឺន) ដុល្លារសហរដ្ឋអាមេរិកឡើយ។ ទឹកប្រាក់ត្រូវបានធានានឹងមានចែងច្បាស់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

**ប្រការ ៧.- ការបង់បុព្វលាភធានារ៉ាប់រង រយៈពេលបង់បុព្វលាភ និងវិធីសាស្ត្របង់បុព្វលាភ**

ការព្រមព្រៀងបង់បុព្វលាភក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ គឺការបង់តាមដំណាក់កាល។

រយៈពេលបង់បុព្វលាភមាន ៦របៀប÷ ការបង់បុព្វលាភរយៈពេល៥ឆ្នាំ ១០ឆ្នាំ ១៥ឆ្នាំ ២០ឆ្នាំ ២៥ឆ្នាំ និង៣០ឆ្នាំ។ អ្នកស្នើសុំធានារ៉ាប់រងអាចជ្រើសរើសរបៀបណាមួយក្នុងចំណោមរបៀបទាំង៦នេះ ប៉ុន្តែនៅពេលដែលរយៈពេលបង់បុព្វលាភដល់កាលកំណត់ អាយុរបស់អ្នកត្រូវបានធានារ៉ាប់រងមិនអាចលើសពី ៦០ឆ្នាំឡើយ។

វិធីសាស្ត្របង់បុព្វលាភមាន ៤របៀប÷ ការបង់ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស និងការបង់ប្រចាំខែ។ អ្នកស្នើសុំអាចជ្រើសរើសរបៀបណាមួយក្នុងចំណោមវិធីសាស្ត្រទាំង ៤របៀបនេះ។

**ប្រការ ៨.- បុព្វលាភធានារ៉ាប់រង និងរយៈពេលអនុគ្រោះ**

១. ចំពោះការបង់បុព្វលាភធានារ៉ាប់រងរាល់ដំណាក់កាល អ្នកស្នើសុំធានារ៉ាប់រងត្រូវអនុវត្តតាមតម្លៃបុព្វលាភដោយផ្អែកតាមតារាងឧបសម្ព័ន្ធ ១ “តារាងអត្រាបុព្វលាភ” ក្រោម ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ ហើយបុព្វលាភនឹងត្រូវបានចែងច្បាស់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើអ្នកស្នើសុំជ្រើសរើសយកវិធីសាស្ត្របង់បុព្វលាភប្រចាំខែ នៅពេលបង់បុព្វលាភលើកដំបូង ក្រុមហ៊ុននឹងតម្រូវឱ្យអ្នកស្នើសុំបង់បុព្វលាភម្តងផ្តាច់សម្រាប់រយៈពេល ៣ខែជាមុន ពុំដូច្នោះទេ កិច្ចសន្យាធានារ៉ាប់រងនេះនឹងមិនមានអនុភាពឡើយ។

២. ក្រោយពេលអ្នកស្នើសុំធានារ៉ាប់រងបានបង់បុព្វលាភដំណាក់កាលដំបូងរួច អ្នកស្នើសុំត្រូវបង់បុព្វលាភដំណាក់កាលក្រោយៗទៀតនៅថ្ងៃដែលបានព្រមព្រៀងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ដើម្បីរក្សានូវអនុភាពរបស់កិច្ចសន្យាធានារ៉ាប់រងនេះ។

ថ្ងៃបន្ទាប់រាល់ខួបប្រចាំឆ្នាំ ថ្ងៃបន្ទាប់រាល់ខួបប្រចាំឆមាស ថ្ងៃបន្ទាប់រាល់ខួបប្រចាំត្រីមាស ឬថ្ងៃបន្ទាប់រាល់ខួបប្រចាំខែនៃកិច្ចសន្យាធានារ៉ាប់រងនេះ គឺជាថ្ងៃព្រមព្រៀងសម្រាប់បង់បុព្វលាភ។

៣. រយៈពេលអនុគ្រោះដែលបានព្រមព្រៀងគ្នាក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ គឺមានរយៈពេល ៦០ថ្ងៃ ហើយត្រូវគណនាគិតចាប់ពីថ្ងៃបន្ទាប់នៃកាលបរិច្ឆេទបង់បុព្វលាភដែលបានបញ្ជាក់ខាងលើ។

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបង់បុព្វលាភក្នុងរយៈពេលអនុគ្រោះ កិច្ចសន្យាធានារ៉ាប់រងនេះនឹងនៅតែមានអនុភាពដដែល។

ក្នុងរយៈពេលអនុគ្រោះ ប្រសិនបើកើតមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រង ដូចបានព្រមព្រៀងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុននឹងនៅតែមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងដដែល ប៉ុន្តែនៅពេលផ្តល់សំណង ក្រុមហ៊ុននឹងដកនូវបុព្វលាភដែលត្រូវបង់ដោយអ្នកស្នើសុំនៅគ្រានោះចេញពីសំណងធានារ៉ាប់រង។

ប្រសិនបើអ្នកស្នើសុំនៅតែមិនទាន់បានបង់បុព្វលាភក្រោយរយៈពេលអនុគ្រោះបានបញ្ចប់ នោះកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវផ្អាក គិតចាប់ពីថ្ងៃបន្ទាប់ដែលរយៈពេលអនុគ្រោះដល់កាលកំណត់ ហើយនៅពេលដែលកិច្ចសន្យាធានារ៉ាប់រងត្រូវបានផ្អាក ក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ។

**ប្រការ ៩.- អត្ថប្រយោជន៍ធានារ៉ាប់រង**

ក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាព ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងដោយផ្អែកទៅតាមការព្រមព្រៀងដូចខាងក្រោម÷

**១. អត្ថប្រយោជន៍នៅរស់រានមានជីវិត**

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិតរហូតដល់អាយុ ៦០ឆ្នាំ គាត់នឹងអាចទទួលបាននូវអត្ថប្រយោជន៍នៅរស់រានមានជីវិតដែលស្មើនឹង ១៥០% នៃទឹកប្រាក់ត្រូវបានធានានៅថ្ងៃបន្ទាប់នៃខួបប្រចាំឆ្នាំនៃកិច្ចសន្យា ដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

**២. អត្ថប្រយោជន៍នៅពេលកិច្ចសន្យាធានារ៉ាប់រងដល់កាលកំណត់**

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត រហូតដល់កិច្ចសន្យាធានារ៉ាប់រងនេះដល់កាលកំណត់ គាត់នឹងអាចទទួលបាននូវអត្ថប្រយោជន៍នៅពេលកិច្ចសន្យាធានារ៉ាប់រងដល់កាលកំណត់ដែលស្មើនឹង ១០០% នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

**៣. សំណងធានារ៉ាប់រងមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺ**

ក. ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺក្រោយរយៈពេលរង់ចាំ ៩០ថ្ងៃបានបញ្ចប់ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងដោយផ្អែកតាមការព្រមព្រៀងដូចខាងក្រោម÷

(១) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពមិនទាន់ដល់គម្រប់ខួប ២ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

(២) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្នុងចន្លោះពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពគម្រប់ខួប ២ឆ្នាំ រហូតដល់ខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១៥០%នៃទឹកប្រាក់ត្រូវបានធានា ដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

(៣) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្រោយខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនទាន់ទទួលបាននូវអត្ថប្រយោជន៍នៅរស់រានមានជីវិតទេ ក្រុមហ៊ុននឹងផ្តល់នូវអត្ថប្រយោជន៍នៅរស់រានមានជីវិតស្របពេលជាមួយគ្នា រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

ខ. ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្នុងរយៈពេលរង់ចាំ ៩០ថ្ងៃ ក្រុមហ៊ុននឹងផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រងដែលបានបង់ទាំងអស់ (ដោយគ្មានការប្រាក់) ទៅកាន់អ្នកស្នើសុំធានារ៉ាប់រងវិញ រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

**៤. សំណងធានារ៉ាប់រងមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ**

សំណងធានារ៉ាប់រងមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុមិនត្រូវបានកំណត់រយៈពេលរង់ចាំ ៩០ថ្ងៃឡើយ÷

ក. ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងជួបគ្រោះថ្នាក់ជាយថាហេតុដែលបណ្តាលឱ្យទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ក្នុងរយៈពេល ១៨០ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុនោះ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងតាមការព្រមព្រៀងដូចខាងក្រោម÷

(១) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងមុនខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ៣០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

(២) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្រោយខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនទាន់ទទួលបាននូវអត្ថប្រយោជន៍នៅរស់រានមានជីវិតទេ ក្រុមហ៊ុននឹងផ្តល់នូវអត្ថប្រយោជន៍នៅរស់រានមានជីវិតស្របពេលជាមួយគ្នា រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

ខ. ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងជួបគ្រោះថ្នាក់ជាយថាហេតុដែលបណ្តាលឱ្យទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ក្រោយរយៈពេល ១៨០ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុនោះ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងតាមការព្រមព្រៀងដូចខាងក្រោម÷

(១) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពមិនទាន់ដល់គម្រប់ខួប ២ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

(២) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្នុងចន្លោះពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពគម្រប់ខួប ២ឆ្នាំ រហូតដល់ខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១៥០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុង

វិញ្ញាបនបត្រធានារ៉ាប់រង រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

(៣) ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើងក្រោយខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រង ដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនទាន់ទទួលបាននូវអត្ថប្រយោជន៍នៅរស់រានមានជីវិតទេ ក្រុមហ៊ុននឹងផ្តល់នូវអត្ថប្រយោជន៍នៅរស់រានមានជីវិតស្របពេលជាមួយគ្នា រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

**ប្រការ ១០.- ការផ្តល់ជូននូវអត្ថប្រយោជន៍បន្ថែមដោយឥតគិតថ្លៃ**

ក្រុមហ៊ុននឹងផ្តល់ជូននូវអត្ថប្រយោជន៍បន្ថែមចំនួន ២ ដោយស្វ័យប្រវត្តិ ដោយអ្នកស្នើសុំធានារ៉ាប់រងមិនចាំបាច់បង់នូវបុព្វលាភបន្ថែម ហើយក៏មិនចាំបាច់បំពេញបែបបទស្នើសុំផ្សេងៗឡើយ។

គិតចាប់ពីថ្ងៃដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពគម្រប់ខួប ២ឆ្នាំ រហូតដល់ខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៦០ឆ្នាំ ប្រសិនបើកិច្ចសន្យាធានារ៉ាប់រងនៅតែមានអនុភាព ហើយបុព្វលាភក្រោមកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានបង់គ្រប់ចំនួនសម្រាប់រយៈពេល ២ឆ្នាំ ក្រុមហ៊ុននឹងផ្តល់ជូននូវអត្ថប្រយោជន៍បន្ថែមចំនួន ២ដូចខាងក្រោម÷

<u>អត្ថប្រយោជន៍បន្ថែមទី១</u>÷ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យលើកដំបូងរកឃើញជំងឺមហារីកសុដន់ មហារីកស្បូន មហារីកមាត់ស្បូន ឬមហារីកក្រពេញប្រូស្តាតដូចបានចែងក្នុងតារាងឧបសម្ព័ន្ធ ៣÷ “៣៨ ប្រភេទនៃជំងឺធ្ងន់ធ្ងរ” ទោះបីជារកឃើញជំងឺមួយ ឬច្រើនប្រភេទក៏ដោយ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ស្របពេលនោះដែរ ក្រុមហ៊ុននឹងលើកលែងនូវបុព្វលាភដែលត្រូវបង់លើកក្រោយៗទៀតក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

ក្រោយពេលដែលក្រុមហ៊ុនផ្តល់នូវសំណងធានារ៉ាប់រងសម្រាប់អត្ថប្រយោជន៍បន្ថែមទី១ ដូចបានរៀបរាប់ខាងលើរួច អត្ថប្រយោជន៍បន្ថែមទី១នេះនឹងត្រូវបញ្ចប់ភ្លាមៗ ប៉ុន្តែមិនប៉ះពាល់ដល់សុពលភាពនៃអត្ថប្រយោជន៍ធានារ៉ាប់រងដូចបានចែងក្រោមប្រការ ៩ ក្នុង ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ និងអត្ថប្រយោជន៍បន្ថែមទី២ខាងក្រោមឡើយ។

<u>អត្ថប្រយោជន៍បន្ថែមទី២</u>÷ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យលើកដំបូងរកឃើញជំងឺធ្ងន់ធ្ងរមួយ ឬច្រើនប្រភេទ ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធ ៣÷ “៣៨ ប្រភេទនៃជំងឺធ្ងន់ធ្ងរ” ក្រៅពីជំងឺមហារីកសុដន់ មហារីកស្បូន មហារីកមាត់ស្បូន និងមហារីកក្រពេញប្រូស្តាត ក្រុមហ៊ុននឹងផ្អែកតាម

អត្ថប្រយោជន៍ធានារ៉ាប់រងណាមួយដូចបានចែងក្រោមប្រការ ៩នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ ផ្តល់សំណងមួយផ្នែកជាមុនជូនអ្នកត្រូវបានធានារ៉ាប់រង ដែលស្មើនឹង ១០០%នៃទឹកប្រាក់ត្រូវបានធានាដូចបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង (ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងបានទទួលនូវអត្ថប្រយោជន៍នៅរស់រានមានជីវិតរួច ក្រុមហ៊ុននឹងមិនផ្តល់សំណងធានារ៉ាប់រងជាមុននេះឡើយ)។ ស្របពេលនោះដែរ ក្រុមហ៊ុននឹងលើកលែងនូវបុព្វលាភដែលត្រូវបង់លើកក្រោយៗទៀតក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

ប៉ុន្តែនៅពេលក្រោយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងកើតមានព្រឹត្តិការណ៍ណាមួយដូចបានចែងក្រោមប្រការ ៩ក្នុង ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ ដែលតម្រូវឲ្យក្រុមហ៊ុនផ្តល់សំណង ក្រុមហ៊ុននឹងដកចេញនូវសំណងដែលក្រុមហ៊ុនបានផ្តល់ជូនជាមុនដូចបានរៀបរាប់ខាងលើ រួចទើបក្រុមហ៊ុនធ្វើការផ្តល់សំណងដែលនៅសេសសល់។

ក្រោយពេលដែលក្រុមហ៊ុនផ្តល់នូវសំណងធានារ៉ាប់រងសម្រាប់អត្ថប្រយោជន៍បន្ថែមទី២ ដូចបានរៀបរាប់ខាងលើរួច អត្ថប្រយោជន៍បន្ថែមទី២នេះនឹងត្រូវបញ្ចប់ភ្លាមៗ ប៉ុន្តែមិនប៉ះពាល់ដល់សុពលភាពនៃអត្ថប្រយោជន៍ធានារ៉ាប់រងដូចបានចែងក្រោមប្រការ ៩ក្នុង ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ និងអត្ថប្រយោជន៍បន្ថែមទី១ខាងលើឡើយ។

**ប្រការ ១១.- ករណីមិនធានា**

១. ក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើនៅពេលដាក់ពាក្យស្នើសុំ អ្នកស្នើសុំធានារ៉ាប់រងមិនបានជូនដំណឹងពិតដល់ក្រុមហ៊ុន ហើយមានការលាក់បាំងអំពីស្ថានភាពសុខភាពដែលមានសភាពមិនល្អ ឬការងារដែលមានហានិភ័យខ្ពស់របស់អ្នកត្រូវបានធានារ៉ាប់រងដូចករណីរៀបរាប់ខាងក្រោម÷

(១) អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរ ដូចបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ៣÷ "៣៨ ប្រភេទនៃជំងឺធ្ងន់ធ្ងរ" ក្រោម ខ និងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះ

(២) អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺរ៉ាំរ៉ៃមួយ ឬច្រើនប្រភេទ ឬជំងឺស្រួចស្រាវ ឬជំងឺសតិអារម្មណ៍

(៣) អ្នកត្រូវបានធានារ៉ាប់រងមានពិការភាព ឬមុខងារភ្នែក ត្រចៀក ឬចលនារាងកាយរបស់អ្នកត្រូវបានធានារ៉ាប់រងមានសភាពមិនប្រក្រតី

(៤) អ្នកត្រូវបានធានារ៉ាប់រងប្រកបមុខរបរមានហានិភ័យខ្ពស់ដែលក្រុមហ៊ុនមិនអាចធានាបាន

(៥) អាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលកិច្ចសន្យាបង្កើតមិនសមស្រប

តាមអាយុសម្រាប់ដាក់ពាក្យស្នើសុំដូចបានចែងក្រោម ខ និងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះ ហើយអ្នកស្នើសុំធានារ៉ាប់រងមានចេតនាលាក់បាំងអំពីរឿងនេះ។

២. ក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងកើតឡើងដោយសារតែករណីណាមួយដូចខាងក្រោម÷

(១) អ្នកស្នើសុំធានារ៉ាប់រង ឬអ្នកទទួលផលមានចេតនាធ្វើឃាត ឬបង្ករបួសទៅលើអ្នកត្រូវបានធានារ៉ាប់រង

(២) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការវាយតប់គ្នា ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬអ្នកត្រូវបានធានារ៉ាប់រងបង្ករបួសលើខ្លួនឯងដោយចេតនា

(៣) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត

(៤) អ្នកត្រូវបានធានារ៉ាប់រងបើកបរក្នុងស្ថានភាពស្រវឹង បើកបរក្នុងស្ថានភាពគ្រោះថ្នាក់ បើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវដែលបានកំណត់ដោយច្បាប់

(៥) អ្នកត្រូវបានធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រ ដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ

(៦) អ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តិល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយពរពោះជំនួសអ្នកដទៃ

(៧) សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរឬការបះបោរប្រដាប់អាវុធ ការផ្ទុះនុយក្លេអ៊ែរ ឬវិទ្យុសកម្មនុយក្លេអ៊ែរ ឬការចម្លងរោគពីនុយក្លេអ៊ែរ ដែលបណ្តាលឲ្យមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រង។

**ប្រការ ១២.- អ្នកទទួលផល**

អ្នកទទួលផលពីសំណងធានារ៉ាប់រងណាមួយ លើកលែងតែសំណងធានារ៉ាប់រងមរណភាពដែលបានព្រមព្រៀងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ គឺជាអ្នកត្រូវបានធានារ៉ាប់រង។ អ្នកទទួលផលដែលបានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រងគឺជាអ្នកទទួលផលសំណងធានារ៉ាប់រងមរណភាព។

នៅពេលបំពេញបែបបទស្នើសុំធានារ៉ាប់រង អ្នកស្នើសុំធានារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងអាចកំណត់អ្នកទទួលផលមួយ ឬច្រើននាក់ ដើម្បីទទួលសំណងធានារ៉ាប់រងមរណភាព។ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងចង់ផ្លាស់ប្តូរអ្នកទទួលផលសំណងធានារ៉ាប់រងមរណភាពក្នុងអំឡុង

ពេលធានារ៉ាប់រង ត្រូវផ្តល់ជូនក្រុមហ៊ុននូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យក្រុមហ៊ុនយល់ព្រមកែប្រែលើកិច្ចសន្យាធានារ៉ាប់រង ឬចេញនូវកិច្ចសន្យាបន្ថែម ទើបការផ្លាស់ប្តូរមានសុពលភាព។

ប្រសិនបើអ្នកទទួលផលសំណងធានារ៉ាប់រងមរណភាពមិនទាន់មានអាយុគ្រប់ ១៨ឆ្នាំ ឬមានជំងឺសតិអារម្មណ៍ នោះនឹងត្រូវកំណត់យកអាណាព្យាបាលរបស់អ្នកទទួលផលរូបនោះ ជាអ្នកតំណាងមានសិទ្ធិទទួលនូវសំណងធានារ៉ាប់រង។

ក្រោយពីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ប្រសិនបើមានព្រឹត្តិការណ៍ណាមួយដូចខាងក្រោមកើតឡើង សំណងនឹងត្រូវក្លាយជាមរតករបស់អ្នកត្រូវបានធានារ៉ាប់រង ក្រុមហ៊ុនត្រូវអនុវត្តកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រង ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា÷

១) អ្នកទទួលផលមិនត្រូវបានកំណត់ ឬមិនកំណត់ច្បាស់លាស់

២) អ្នកទទួលផលទទួលមរណភាពមុនអ្នកត្រូវបានធានារ៉ាប់រង ហើយគ្មានអ្នកទទួលផលផ្សេងទៀត

៣)អ្នកទទួលផលបាត់បង់សិទ្ធិទទួលអត្ថប្រយោជន៍ ឬបោះបង់សិទ្ធិទទួលផលប្រយោជន៍នេះដោយអនុលោមតាមច្បាប់ ហើយគ្មានអ្នកទទួលផលផ្សេងទៀត

៤) ប្រសិនបើអ្នកទទួលផល និងអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពដោយសារគ្រោះថ្នាក់តែមួយ ហើយមិនអាចកំណត់លំដាប់នៃការទទួលមរណភាពបាន ត្រូវចាត់ទុកថាអ្នកទទួលផលទទួលមរណភាពមុនអ្នកត្រូវបានធានារ៉ាប់រង។

**ប្រការ ១៣.- ការជូនដំណឹងអំពីព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រង**

ក្រោយពេលអ្នកស្នើសុំធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលបានដឹងពីព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងណាមួយ ត្រូវជូនដំណឹងឲ្យក្រុមហ៊ុនឲ្យបានទាន់ពេល ឬក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ។ ប្រសិនបើមានចេតនាមិនជូនដំណឹងដល់ក្រុមហ៊ុនឲ្យបានទាន់ពេលវេលា បណ្តាលឲ្យក្រុមហ៊ុនធានារ៉ាប់រងអលទ្ធភាពក្នុងការកំណត់អំពីមូលហេតុ កម្រិតខូចខាត និងលក្ខណៈឧបទ្ទវហេតុនោះ ក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងសម្រាប់ផ្នែកណាមួយដែលខ្លួនមិនអាចកំណត់បានទេ លើកលែងតែក្រុមហ៊ុនបានដឹងពីស្ថានភាពនៃឧបទ្ទវហេតុនោះតាមរយៈមធ្យោបាយផ្សេងទៀត។

**ប្រការ ១៤.- ការទាមទារ និងការទូទាត់សំណង**

១. អ្នកទទួលផលត្រូវបំពេញបែបបទស្នើសុំទាមទារសំណង និងផ្តល់ភស្តុតាង ព្រមទាំងឯកសារតម្រូវផ្សេងៗទៀតសម្រាប់ការទាមទារសំណង ដូចមានចែងនៅក្នុងប្រការ ១៥ ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។ ប្រសិនបើភស្តុតាង និងឯកសារផ្សេងៗនៅមិនទាន់គ្រប់គ្រាន់ ក្រុមហ៊ុននឹងជូនដំណឹងទៅអ្នកទទួល

ផលឱ្យផ្តល់ឯកសារ និងភស្តុតាងបន្ថែមទៀតភ្លាម។ អ្នកទទួលផលត្រូវមានកាតព្វកិច្ចផ្តល់នូវភស្តុតាងពាក់ព័ន្ធ និងឯកសារដែលបានបញ្ជាក់ផ្សេងៗខាងលើឱ្យបានឆាប់រហ័ស។

២. នៅពេលទទួលសំណុំបែបបទស្នើសុំទាមទារសំណង និងភស្តុតាង ក៏ដូចជាឯកសារដូចដែលបានបញ្ជាក់នៅខាងលើនេះ ក្រុមហ៊ុននឹងផ្ទៀងផ្ទាត់ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ ឬ ២០ថ្ងៃនៃថ្ងៃធ្វើការសម្រាប់ករណីស្មុគស្មាញ។

ក្រោយពិនិត្យផ្ទៀងផ្ទាត់រួច ប្រសិនបើត្រូវបានបញ្ជាក់ថាត្រូវធ្វើការផ្តល់សំណង នោះក្រុមហ៊ុននឹងផ្តល់សំណងក្នុងរយៈពេល ២ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានព្រមព្រៀងគ្នាជាមួយអ្នកទទួលផលលើការផ្តល់សំណងនេះ។ ក្រោយពិនិត្យផ្ទៀងផ្ទាត់រួច ប្រសិនបើបញ្ជាក់ថាមិនត្រូវធ្វើការផ្តល់សំណងទេនោះក្រុមហ៊ុនធានារ៉ាប់រងនឹងចេញលិខិតជូនដំណឹងមួយស្តីពីការបដិសេធក្នុងការផ្តល់សំណងធានារ៉ាប់រងទៅអ្នកស្នើសុំទាមទារសំណងក្នុងរយៈពេល ២ថ្ងៃនៃថ្ងៃធ្វើការ ដោយមានការពន្យល់បញ្ជាក់អំពីមូលហេតុនៃការបដិសេធនោះផងដែរ។

៣. រយៈពេលមានប្រសិទ្ធភាពសម្រាប់អ្នកទទួលផលធ្វើការស្នើសុំទាមទារសំណងធានារ៉ាប់រងគឺមានរយៈពេល ៥ឆ្នាំ ដោយឡែកចំពោះរយៈពេលមានប្រសិទ្ធភាពសម្រាប់ការស្នើសុំទាមទារសំណងធានារ៉ាប់រងសម្រាប់ជំងឺធ្ងន់ធ្ងរគឺមានរយៈពេលត្រឹម ១ឆ្នាំប៉ុណ្ណោះ គិតចាប់ពីថ្ងៃដែលអ្នកទទួលផលបានដឹង ឬគួរដឹងអំពីព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងនោះ។

**ប្រការ ១៥.- ភស្តុតាង និងឯកសារតម្រូវសម្រាប់ការទាមទារសំណងធានារ៉ាប់រង**

១. កិច្ចសន្យាធានារ៉ាប់រង ឬភស្តុតាងផ្សេងទៀតដែលបង្ហាញថាកិច្ចសន្យាធានារ៉ាប់រងនៅមានអនុភាព

២. ឯកសារបញ្ជាក់ពីអត្តសញ្ញាណស្របច្បាប់ដែលមានសុពលភាពរបស់អ្នកទទួលផល

៣. ភស្តុតាង និងឯកសារដែលអាចបង្ហាញពីអង្គហេតុ លក្ខណៈដើម និងមូលហេតុនៃគ្រោះថ្នាក់ដែលមាន

៤. ប្រសិនបើមានអ្នកតំណាងម្នាក់ត្រូវបានតែងតាំងដើម្បីទាមទារសំណងធានារ៉ាប់រង ត្រូវផ្តល់នូវលិខិតប្រគល់សិទ្ធិតំណាង និងឯកសារបញ្ជាក់អត្តសញ្ញាណស្របច្បាប់របស់អ្នកតំណាងនោះ

៥. ប្រសិនបើទាមទារសំណងធានារ៉ាប់រងពិការភាព ត្រូវមានលិខិតបញ្ជាក់ពីកម្រិតពិការភាព ឬលិខិតយថាភូតស្តីពីកម្រិតនៃពិការភាពផ្នែករាងកាយ ដែលចេញដោយស្ថាប័នវេជ្ជសាស្រ្ត ឬស្ថាប័នប្រហាក់ប្រហែលស្របច្បាប់ផ្សេងទៀតដែលមានសិទ្ធិបញ្ជាក់ពីកម្រិតនៃពិការភាព។ ប្រសិនបើអ្នកត្រូវបាន

ធានារ៉ាប់រងទទួលរងពិការភាពដោយសារតែគ្រោះថ្នាក់ជាយថាហេតុ ត្រូវផ្អែកលើលទ្ធផលវាយតម្លៃអំពីកម្រិតពិការភាពរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងរយៈពេល ១៨០ថ្ងៃគិតចាប់ពីថ្ងៃកើតហេតុនោះ។

៦. ប្រសិនបើទាមទារសំណងធានារ៉ាប់រងជំងឺធ្ងន់ធ្ងរ ត្រូវផ្តល់លិខិតបញ្ជាក់សុខភាព និងឯកសារយោង ដែលភ្ជាប់ជាមួយនឹងរោគសញ្ញារបស់អ្នកត្រូវបានធានារ៉ាប់រង របាយការណ៍ស្តីពីការធ្វើតេស្តឈាម និងរបាយការណ៍ស្តីពីការធ្វើរោគវិនិច្ឆ័យវេជ្ជសាស្ត្រដោយឧបករណ៍ផ្សេងទៀតចេញដោយមន្ទីរពេទ្យដែលមានសមត្ថភាពខ្ពស់ក្នុងការធ្វើរោគវិនិច្ឆ័យចំពោះជំងឺធ្ងន់ធ្ងរ។

ក្រោយពេលក្រុមហ៊ុនបានផ្ទៀងផ្ទាត់ភស្តុតាង ឬឯកសារបញ្ជាក់ដូចបានរៀបរាប់ខាងលើរួច ហើយនៅតែមិនគ្រប់គ្រាន់ក្នុងការសម្រេចលើកចុងក្រោយ ក្រុមហ៊ុនមានសិទ្ធិស្នើសុំឱ្យអ្នកទទួលផលផ្តល់ជូននូវឯកសារបញ្ជាក់បន្ថែម។

**ប្រការ ១៦.- ការបាត់ខ្លួន**

ក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាព ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបាត់ខ្លួន ហើយត្រូវបានប្រកាសថាស្លាប់ដោយតុលាការ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងដោយផ្អែកតាមអត្ថប្រយោជន៍ធានារ៉ាប់រងដូចបានចែងក្រោមប្រការ ៩ កថាខណ្ឌទី៣ នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។ ប្រសិនបើមានភស្តុតាងអាចបញ្ជាក់បានថាអ្នកត្រូវបានធានារ៉ាប់រងបាត់ខ្លួនដោយសារតែការប៉ះទង្គិចយន្តហោះ ឬការក្រឡាប់កប៉ាល់សមុទ្រ ឬការបាក់អណ្តូងរ៉ែកប់ពីលើ ក្រុមហ៊ុននឹងផ្តល់សំណងធានារ៉ាប់រងដោយផ្អែកតាមអត្ថប្រយោជន៍ធានារ៉ាប់រងដូចបានចែងក្រោមប្រការ ៩ កថាខណ្ឌទី៤ នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់ភ្លាមៗ។

កាលបរិច្ឆេទទទួលមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវកំណត់ដោយផ្អែកតាមកាលបរិច្ឆេទទទួលមរណភាពចេញដោយតុលាការ។

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងត្រូវបានរកឃើញសារជាថ្មី ឬត្រូវបានបញ្ជាក់ថានៅមានជីវិតបន្ទាប់ពីការប្រកាសមរណភាព ក្រុមហ៊ុននឹងប្រមូលនូវសំណងធានារ៉ាប់រងដែលខ្លួនបានផ្តល់ពីអ្នកទទួលផលវិញ។ ប្រសិនបើក្រុមហ៊ុនបានដឹងច្បាស់ថាអ្នកទទួលផលបានកុហកអំពីការបាត់ខ្លួនរបស់អ្នកត្រូវបានធានារ៉ាប់រង ក្រុមហ៊ុននឹងមិនត្រឹមតែប្រមូលនូវសំណងធានារ៉ាប់រងដែលខ្លួនបានផ្តល់ពីអ្នកទទួលផលវិញឡើយ ថែមទាំងបញ្ចប់នូវកិច្ចសន្យាធានារ៉ាប់រងភ្លាម ហើយក្រុមហ៊ុននឹងមិនទទួលនូវសំណើសុំឱ្យក្រុមហ៊ុនផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រង ឬតម្លៃសាច់ប្រាក់ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះឡើយ។



អាគារកាណាឌីយ៉ាជាន់ទី26 CDEF វិថីព្រះអង្គឌួងលេខ315 ក្រុងភ្នំពេញ 26th Floor CDEF Canadia Tower 315 Ang Doung Street Phnom Penh Tel: 023989218

**ប្រការ ១៧.- ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង**

ក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាធានារ៉ាប់រងនេះ លើកលែងតែមានការព្រមព្រៀងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងដោយមូលហេតុផ្សេងៗបាន រួមបញ្ចូលទាំងការស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងដោយសារតែក្រុមហ៊ុនបដិសេធផ្តល់សំណងធានារ៉ាប់រងផងដែរ។

កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់នៅពេលដែលក្រុមហ៊ុនទទួលបានសំណើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ហើយក្រុមហ៊ុននឹងទូទាត់តម្លៃសាច់ប្រាក់នៅពេលនោះជូនទៅកាន់អ្នកស្នើសុំធានារ៉ាប់រង។ ក្នុងករណីអ្នកស្នើសុំធានារ៉ាប់រង ឬអ្នកទទួលផលបាត់បង់សិទ្ធិទទួលតម្លៃសាច់ប្រាក់ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ការផ្តល់ត្រឡប់នូវតម្លៃសាច់ប្រាក់នឹងត្រូវដោះស្រាយដោយផ្អែកតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬបទបញ្ញត្តិចេញដោយក្រសួងពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះកិច្ចសន្យាធានារ៉ាប់រងដែលធ្លាប់បានទទួលនូវសំណងធានារ៉ាប់រងមួយផ្នែកជាមុន ព្រមទាំងស្របពេលនោះទទួលបានការលើកលែងបុព្វលាភធានារ៉ាប់រង ក្រុមហ៊ុននឹងមិនទទួលសំណើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះឡើយ។

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងបញ្ចប់កិច្ចសន្យាធានារ៉ាប់រងក្រោយរយៈពេលសម្រេចចិត្តដល់កាលកំណត់ អ្នកស្នើសុំធានារ៉ាប់រងត្រូវទទួលខុសត្រូវចំពោះការខាតបង់ផ្នែកសេដ្ឋកិច្ចដែលកើតឡើងពីការបញ្ចប់កិច្ចសន្យានោះ។

**ប្រការ ១៨.- តម្លៃសាច់ប្រាក់**

តម្លៃសាច់ប្រាក់សំដៅទៅលើប្រាក់ដែលត្រូវផ្តល់ត្រឡប់ទៅឲ្យអ្នកស្នើសុំធានារ៉ាប់រងវិញដោយក្រុមហ៊ុននៅពេលកិច្ចសន្យាត្រូវបានបញ្ចប់ក្នុងអំឡុងពេលធានារ៉ាប់រង ដោយផ្អែកទៅតាមបទបញ្ញាតិដូចមានចែងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។ តម្លៃសាច់ប្រាក់រាល់ចុងឆ្នាំនីមួយៗនៃកិច្ចសន្យាធានារ៉ាប់រងនេះត្រូវអនុលោមតាមតារាងឧបសម្ព័ន្ធ ៤÷ «តារាងតម្លៃសាច់ប្រាក់រាល់ចុងឆ្នាំនីមួយៗនៃកិច្ចសន្យាធានារ៉ាបរង» ក្រោម ខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ ហើយនឹងត្រូវបានចែងច្បាស់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

**ប្រការ ១៩.- ការផ្អាក និងការបន្តអនុភាពរបស់កិច្ចសន្យាធានារ៉ាប់រងឡើងវិញ**

១. កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវផ្អាក ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងខកខានមិនបានបង់បុព្វលាភធានារ៉ាប់រងឲ្យបានទាន់ពេលវេលាយោងតាមបទប្បញ្ញត្តិនៃកិច្ចសន្យាធានារ៉ាប់រងនេះ ហើយក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ។

ក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីការផ្អាកកិច្ចសន្យាធានារ៉ាប់រង អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបន្តអនុភាពរបស់កិច្ចសន្យាធានារ៉ាប់រងឡើងវិញបាន ហើយកិច្ចសន្យាធានារ៉ាប់រងនឹងមានអនុភាពឡើងវិញចាប់ផ្តើមពីថ្ងៃបន្ទាប់នៃថ្ងៃដែលអ្នកស្នើសុំធានារ៉ាប់រងបានបំពេញបែបបទដើម្បីបន្តអនុភាពរបស់កិច្ចសន្យាធានារ៉ាប់រង និងបានបង់បុព្វលាភរួមជាមួយនឹងការប្រាក់ ព្រមទាំងបានបង់ប្រាក់ដែលនៅសល់ផ្សេងទៀតរួមជាមួយការប្រាក់គ្រប់ចំនួន។

ការប្រាក់ដែលបានរៀបរាប់ខាងលើត្រូវបានគណនាយោងតាមអត្រាការប្រាក់ ៦% ក្នុងមួយឆ្នាំ។

២. ក្រោយពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានផ្អែកគ្រប់រយៈពេលពីរឆ្នាំ កិច្ចសន្យាធានារ៉ាប់រងនេះនឹងអស់អនុភាពជាអចិន្ត្រៃយ៍។ ក្រុមហ៊ុននឹងមិនទទួលយកសំណើសុំបន្តអនុភាពរបស់កិច្ចសន្យាធានារ៉ាប់រងឡើងវិញឡើយ។ អ្នកស្នើសុំធានារ៉ាប់រងត្រូវបំពេញបែបបទបញ្ចប់កិច្ចសន្យាធានារ៉ាប់រងឱ្យបានទាន់ពេលវេលា និងទទួលយកនូវតម្លៃសាច់ប្រាក់របស់កិច្ចសន្យាធានារ៉ាប់រងនៅពេលដែលកិច្ចសន្យាធានារ៉ាប់រងត្រូវបានផ្អាកនោះ។ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងមិនមកទទួលទាន់ពេលវេលា ក្រុមហ៊ុននឹងមិនគិតការប្រាក់ជូនឡើយ។

**ប្រការ ២០.- ការពន្យល់ឲ្យបានច្បាស់ និងការផ្តល់ព័ត៌មានពិត**

នៅពេលអនុវត្តកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនត្រូវពន្យល់អ្នកស្នើសុំធានារ៉ាប់រងឲ្យបានច្បាស់អំពីខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រង។

ចំពោះករណីមិនធានាដែលមានចែងនៅក្នុង ខ និងលក្ខខណ្ឌធានារ៉ាប់រង និងលក្ខខណ្ឌចាំបាច់ផ្សេងទៀត ដូចជាការទទួលខុសត្រូវចំពោះការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារតែការបញ្ចប់កិច្ចសន្យាធានារ៉ាប់រងក្រោយរយៈសម្រេចចិត្ត ក្រុមហ៊ុនត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នៅលើសៀវភៅផែនការធានារ៉ាប់រង ពាក្យស្នើសុំធានារ៉ាប់រង ឬឯកសារធានារ៉ាប់រងផ្សេងទៀតដើម្បីឲ្យអ្នកស្នើសុំធានារ៉ាប់រងមានការប្រុងប្រយ័ត្ន។

ក្រុមហ៊ុនអាចសាកសួរអ្នកស្នើសុំធានារ៉ាប់រងអំពីព័ត៌មានផ្ទាល់ខ្លួន ស្ថានភាពសុខភាព ប្រវត្តិជំងឺពីមុន ប្រវត្តិជំងឺក្នុងគ្រួសាររបស់អ្នកស្នើសុំធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តកិច្ចសន្យាធានារ៉ាប់រង។ អ្នកស្នើសុំធានារ៉ាប់រងត្រូវអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានពិតដោយសុចរិតត្រឹមត្រូវ និងត្រូវទទួលខុសចំពោះមុខច្បាប់។ បើមិនដូច្នោះទេ នឹងធ្វើឲ្យកិច្ចសន្យាធានារ៉ាប់រងបាត់បង់នូវអនុភាព។

ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងគ្មានចេតនាមិនអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានពិត ដែលបណ្តាលឲ្យក្រុមហ៊ុនអលទ្ធភាពក្នុងការសម្រេចចិត្តថាតើត្រូវទទួលខុសត្រូវ ឬត្រូវទទួលខុសត្រូវដោយរបៀបណា នោះក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ។ ប្រសិនអ្នកស្នើសុំធានារ៉ាប់រងស្នើសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងដោយសារតែមូលហេតុនេះ ក្រុមហ៊ុននឹងផ្តល់ត្រឡប់នូវតម្លៃសាច់ប្រាក់ជូនទៅកាន់អ្នកស្នើសុំធានារ៉ាប់រងវិញ រួចកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបញ្ចប់។

ប្រសិនបើក្រុមហ៊ុនបានដឹងថាអ្នកស្នើសុំធានារ៉ាប់រងមានចេតនាកុហក ឬមិនផ្តល់ព័ត៌មានពិត ក្រុមហ៊ុននឹងបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះនៅថ្ងៃដែលបានដឹងនោះ ហើយក្រុមហ៊ុននឹងមិនផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រង និងតម្លៃសាច់ប្រាក់ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះឡើយ។ ចំពោះការកើតហេតុការណ៍ស្ថិតក្រោមការធានារ៉ាប់រងមុនពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានបញ្ចប់ ក្រុមហ៊ុនក៏មិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ។

**ប្រការ ២១.- ការកែប្រែខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រង**

១. ក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាធានារ៉ាប់រងនេះ អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំកែប្រែខ្លឹមសារមួយចំនួននៃកិច្ចសន្យាធានារ៉ាប់រងនេះបាន ក្រុមហ៊ុននឹងទទួលនូវសំណើសុំកែប្រែខ្លឹមសាររបស់អ្នកស្នើសុំធានារ៉ាប់រងជាលាយលក្ខណ៍អក្សរ។ មុនពេលដែលការកែប្រែមានសុពលភាព ក្រុមហ៊ុនធានារ៉ាប់រង និងអ្នកស្នើសុំធានារ៉ាប់រងអាចចរចាលើការកែប្រែខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រងនេះបាន ព្រមទាំងអាចព្រមព្រៀងនូវកាលបរិច្ឆេទមានសុពលភាពនៃការកែប្រែនេះផងដែរ។ ក្រោយពេលភាគីទាំងសងខាងយល់ស្របលើការកែប្រែរួច ក្រុមហ៊ុននឹងចេញ ឬភ្ជាប់នូវកិច្ចសន្យាបន្ថែមដែលអាចបញ្ជាក់ថាការកែប្រែអាចមានសុពលភាពលើកិច្ចសន្យាធានារ៉ាប់រងនេះ។

២. នៅពេលដែលអ្នកស្នើសុំធានារ៉ាប់រង ឬក្រុមហ៊ុនបានដឹងថាអាយុពិតរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានបំពេញខុស អ្នកស្នើសុំធានារ៉ាប់រង ឬក្រុមហ៊ុនត្រូវចុះកិច្ចព្រមព្រៀងកែប្រែព័ត៌មានអំពីអាយុនោះជាលាយលក្ខណ៍អក្សរឲ្យបានទាន់ពេលវេលា ព្រមទាំងគណនាបុព្វលាភធានារ៉ាប់រងសារជាថ្មីដោយផ្អែកតាមអាយុពិតរបស់អ្នកត្រូវបានធានារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងនឹងត្រូវប្រគល់ជូនអ្នកស្នើសុំធានារ៉ាប់រងវិញ ប្រសិនបើត្រូវបានទូទាត់លើស ហើយត្រូវបន្ថែមមកឲ្យក្រុមហ៊ុនធានារ៉ាប់រងវិញ ប្រសិនបើត្រូវបានទូទាត់ខ្វះ។ ក្នុងករណីមានការទាក់ទងទៅនឹងការគណនាការប្រាក់ ត្រូវយកអត្រាការប្រាក់ ៦%ក្នុងមួយឆ្នាំមកគណនា។ ប្រសិនអ្នកស្នើសុំធានារ៉ាប់រងផ្តល់ព័ត៌មានមិនពិតអំពីអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយអាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រងមិនសមស្របទៅនឹងលក្ខខណ្ឌក្នុងការដាក់ពាក្យស្នើសុំធានារ៉ាប់រង

ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុននឹងបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះភ្លាមៗ។ អ្នកស្នើសុំធានារ៉ាប់រងត្រូវសហការជាមួយក្រុមហ៊ុនធានារ៉ាប់រងដើម្បីបំពេញបែបបទបញ្ចប់កិច្ចសន្យាធានារ៉ាប់រងឲ្យបានទាន់ពេលវេលា ព្រមទាំងទទួលត្រឡប់នូវបុព្វលាភដែលបានបង់ទាំងអស់ (ដោយគ្មានការប្រាក់) ទៅវិញ។

ចំពោះស្ថានភាពដូចបានរៀបរាប់ខាងលើ ប្រសិនបើមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងកើតឡើងនៅមុនពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមិនទាន់បានកែប្រែរួច រាល់ព្រឹត្តិការណ៍ដែលកើតហេតុមុនកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពគម្រប់ខួប ២ឆ្នាំ ក្រុមហ៊ុននឹងមិនផ្តល់សំណងធានារ៉ាប់រងឡើយ ហើយក្រុមហ៊ុននឹងគ្រាន់តែផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រង (ដោយគ្មានការប្រាក់) ទៅឲ្យអ្នកស្នើសុំធានារ៉ាប់រងវិញប៉ុណ្ណោះ។ ចំពោះព្រឹត្តិការណ៍ដែលកើតឡើងក្រោយពេលកិច្ចសន្យាធានារ៉ាប់រងនេះមានអនុភាពគម្រប់ខួប២ឆ្នាំ ក្រុមហ៊ុននឹងនៅតែផ្តល់សំណងធានារ៉ាប់រង ប៉ុន្តែចំនួនសំណងធានារ៉ាប់រងដែលត្រូវផ្តល់ឲ្យត្រូវគណនាដោយកែតម្រូវទៅតាមអាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង។

ចំពោះស្ថានភាពដូចបានរៀបរាប់ខាងលើ ប្រសិនបើក្រុមហ៊ុនមានភស្តុតាងបញ្ជាក់ថាអ្នកស្នើសុំធានារ៉ាប់រងកុហក ឬមានចេតនាលាក់បាំងពីអាយុពិតរបស់អ្នកត្រូវបានធានារ៉ាប់រង ឬមានចេតនាពន្យារពេលក្នុងការបំពេញបែបបទកែប្រែអាយុ ឬបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុនមានសិទ្ធិបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះ ហើយក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវផ្តល់សំណងធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះឡើយ ព្រមទាំងមិនផ្តល់ត្រឡប់នូវបុព្វលាភធានារ៉ាប់រង និងតម្លៃសាច់ប្រាក់ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះឡើយ។

៣. ក្នុងករណីដែលអ្នកស្នើសុំធានារ៉ាប់រងប្តូរអាសយដ្ឋានទំនាក់ទំនង និងព័ត៌មានទំនាក់ទំនងរបស់គាត់ អ្នកស្នើសុំធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមមកកាន់ក្រុមហ៊ុនធានារ៉ាប់រង។ ប្រសិនបើអ្នកស្នើសុំធានារ៉ាប់រងខកខានក្នុងការអនុវត្តកាតព្វកិច្ចនេះ ក្រុមហ៊ុននឹងជូនដំណឹងផ្សេងៗតាមរយៈអាសយដ្ឋានទំនាក់ទំនង និងព័ត៌មានទំនាក់ទំនងចុងក្រោយដែលក្រុមហ៊ុនបានស្គាល់ទៅអ្នកស្នើសុំធានារ៉ាប់រង។

**ប្រការ ២២.- ការដោះស្រាយវិវាទ**

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ។

កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានប្រើប្រាស់ជាភាសាខ្មែរ ហើយក៏អាចផ្តល់ជូនជាភាសាអង់គ្លេស និងភាសាចិនផងដែរ ប៉ុន្តែក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយកភាសាខ្មែរជាគោល។

**ប្រការ ២៣.- និយមន័យ**

ក្រុមហ៊ុន÷ សំដៅលើក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្គ្រេន ឆាយណា ឡាយហ្វ៍ អ៊ិនសួរេន ម.ក។

អាយុ÷ សំដៅដល់អាយុដែលត្រូវបានគណនាដោយផ្អែកលើថ្ងៃខែឆ្នាំកំណើតដែលបានបញ្ជាក់នៅលើអត្តសញ្ញាណបណ្ណដែលត្រូវនឹងអាយុសូន្យ គិតចាប់ពីថ្ងៃខែឆ្នាំកំណើត និងកើនឡើងមួយឆ្នាំនៅពេលដែលរយៈពេលមួយឆ្នាំបានកន្លងផុតទៅ ហើយវានឹងមិនត្រូវបានរាប់ជាមួយឆ្នាំទេប្រសិនបើរយៈពេលមួយឆ្នាំមិនទាន់កន្លងផុត។

ឯកសារបញ្ជាក់អត្តសញ្ញាណស្របច្បាប់÷ សំដៅទៅលើលិខិតបញ្ជាក់ ឬឯកសារ ដូចជាអត្តសញ្ញាណបណ្ណ លិខិតឆ្លងដែនជាដើម ដែលចេញដោយរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ។

គ្រោះថ្នាក់ជាយថាហេតុ÷ សំដៅទៅលើគ្រោះថ្នាក់ ដែលជាគ្រោះថ្នាក់ខាងក្រៅ មិនអាចរំពឹងទុកបាន មិនមានឆន្ទៈ គ្មានជំងឺ និងបង្កឱ្យមានរបួសដោយផ្ទាល់។ គ្រោះថ្នាក់ជាយថាហេតុ រួមមានការផ្ទុះ ការដួលរលំ ការរលាក ការប៉ះទង្គិចគ្នា ផ្លេកបន្ទោរ ការឆក់ចរន្តអគ្គិសនី គ្រេចថ្លោះ ការកក ខ្យល់គរ ការលង់ទឹក ការថប់ដង្ហើម ការដួល ការពុល សត្វទិច ឬខាំ ការប៉ះទង្គិចយានយន្ត ទូក ឬយន្តហោះ គ្រោះថ្នាក់ការងារដែលបណ្តាលមកពីការធ្វើការងារលើសម៉ោង។ ការស្លាប់ភ្លាមៗមិនត្រូវបានចាត់ទុកថាជាការស្លាប់ដោយគ្រោះថ្នាក់ជាយថាហេតុឡើយ (ការស្លាប់ភ្លាមៗ សំដៅទៅលើមរណភាពភ្លាមៗ ដោយគ្មានអំពើហិង្សាលើអ្នកស្លាប់ ដែលមើលទៅមានសុខភាពល្អក្នុងរយៈពេល ២៤ម៉ោងបន្ទាប់ពីមានរោគសញ្ញាកើតឡើងតាមរយៈជំងឺដែលបានកំណត់ ដំណើរការខុសប្រក្រតី ឬមូលហេតុផ្សេងទៀត។ ការស្លាប់ភ្លាមៗនឹងត្រូវកំណត់ដោយអ្នកធ្វើរោគវិនិច្ឆ័យនៅមន្ទីរពេទ្យ និងផ្តល់យថាភូតដោយមន្ត្រីប៉ូលីស)។

ពិការភាពជាអចិន្ត្រៃយ៍÷ សំដៅលើស្ថានភាពដូចបានចែងក្នុងតារាងឧបសម្ព័ន្ធ ២ "តារាងពិការភាពជាអចិន្ត្រៃយ៍នៃធានារ៉ាប់រងបុគ្គល" ក្រោមប្រការ២៤ នៃខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ។

ជំងឺធ្ងន់ធ្ងរ÷ សំដៅលើស្ថានភាពដូចបានចែងក្នុងតារាងឧបសម្ព័ន្ធ ៣÷ "៣៨ ប្រភេទនៃជំងឺធ្ងន់ធ្ងរ" ក្រោមប្រការ២៤ នៃខ និងលក្ខខណ្ឌធានារ៉ាប់រងនេះ។

ខួបប្រចាំឆ្នាំនៃកិច្ចសន្យា÷ សំដៅលើថ្ងៃ និងខែដដែលជារៀងរាល់ឆ្នាំនៃកាលបរិច្ឆេទមានសុពលភាពរបស់កិច្ចសន្យាធានារ៉ាប់រង។ ឧទាហរណ៍÷ កាលបរិច្ឆេទមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងគឺ

ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០០(នៅពេលនោះ អ្នកត្រូវបានធានារ៉ាប់រងមានអាយុ ៣០ឆ្នាំ) ដូចនេះខួបប្រចាំឆ្នាំនៃកិច្ចសន្យាគឺ ថ្ងៃទី ០៥ ខែ មេសា ២០០១, ថ្ងៃទី ០៥ ខែ មេសា ២០០២, ថ្ងៃទី ០៥ ខែ មេសា ២០០៣ ......... ហើយខួបប្រចាំឆ្នាំនៃកិច្ចសន្យានៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ៦០ឆ្នាំគឺ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០៣០។

ឆ្នាំនៃបណ្ណសន្យារ៉ាប់រង÷ ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចសន្យាធានារ៉ាប់រង (ឬខួបប្រចាំឆ្នាំនៃថ្ងៃចូលជាធរមាន) ដល់ថ្ងៃខែឆ្នាំដែលមានប្រសិទ្ធភាពក្នុងឆ្នាំបន្ទាប់។

ការផ្អាកកិច្ចសន្យា ÷ សំដៅលើការបាត់បង់អនុភាពរបស់កិច្ចសន្យាជាបណ្តោះអាសន្ន ដោយសារតែមូលហេតុណាមួយក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា។ ប្រសិនបើកើតមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងក្នុងអំឡុងពេលដែលកិច្ចសន្យាត្រូវបានផ្អាក ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ។ ចំពោះកិច្ចសន្យាដែលត្រូវបានផ្អាកមិនទាន់គ្រប់រយៈពេល២ឆ្នាំ អ្នកស្នើសុំធានារ៉ាប់រងអាចស្នើសុំបន្តអនុភាពរបស់កិច្ចសន្យាឡើងវិញបាន ប៉ុន្តែត្រូវមានការយល់ព្រមពីក្រុមហ៊ុនធានារ៉ាប់រង។

ការបញ្ចប់កិច្ចសន្យា÷ សំដៅលើការបាត់បង់អនុភាពទាំងស្រុង និងមិនអាចបន្តអនុភាពឡើងវិញរបស់កិច្ចសន្យា ដោយសារតែកើតមានមូលហេតុស្របច្បាប់ណាមួយ ឬមូលហេតុស្ថិតក្រោមការព្រមព្រៀងណាមួយក្នុងកិច្ចសន្យា ក្រោយពេលដែលកិច្ចសន្យាចូលជាធរមាន (លើកលែងចំពោះកិច្ចសន្យាដែលមានការព្រមព្រៀងពិសេស)។ ប្រសិនបើកើតមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងក្រោយពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ។

គ្រឿងញៀន÷ សំដៅលើថ្នាំអាភៀន ហេរ៉ូអ៊ីន មេតំហ្វេតាមីន ថ្នាំម៉ុនហ្វីន ថ្នាំញៀនកូកាអ៊ីនគីទីន (K powder) ដែលកំណត់ដោយអង្គការសហប្រជាជាតិ និងគ្រឿងញៀន និងគ្រឿងញៀនផ្សេងទៀតដែលត្រូវបានហាមឃាត់ លើកលែងតែថ្នាំពេទ្យដែលមានសមាសធាតុគ្រឿងញៀន ប៉ុន្តែត្រូវបានចេញវេជ្ជបញ្ជាដោយវេជ្ជបណ្ឌិត និងត្រូវបានប្រើប្រាស់តាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតសម្រាប់ការព្យាបាលជំងឺ។

បើកបរក្នុងស្ថានភាពស្រវឹង÷ សំដៅទៅលើព្រឹត្តិការណ៍ដែលអ្នកបើកបរត្រូវបានធ្វើតេស្ត ឬផ្ទៀងផ្ទាត់កម្រិតជាតិអាល់កុល ដែលអាចផ្ទុកបរិមាណចំនួនមួយរយមីលីលីត្រ ដែលមាននៅក្នុងឈាមរបស់

បុគ្គលនោះ ដែលកម្រិតជាតិអាល់កុលនោះអាចឈានដល់ ឬលើសពីកម្រិតដែលកំណត់ដោយច្បាប់ ឬរដ្ឋាភិបាល។

ការបើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ÷ សំដៅទៅលើស្ថានភាពណាមួយខាងក្រោម÷

(១) មិនទទួលបានសិទ្ធិបើកបរ

(២) បើកបររថយន្តដែលមិនត្រូវគ្នានឹងបណ្ណបើកបរ

(៣) មានអាជ្ញាបណ្ណបើកបរមិនមានគុណវុឌ្ឍន៍

(៤) មានអាជ្ញាបណ្ណរៀនសូត្រនិងរៀនបើកឡានដោយគ្មានការណែនាំពីអ្នកបង្រៀនបើកបរ ឬមិនអនុវត្តតាមពេលកំណត់ និងរៀនតាមផ្លូវបើកបរ។

ការបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវ÷ សំដៅទៅលើស្ថានភាពណាមួយខាងក្រោម÷

(១) យានយន្តដែលត្រូវបានលុបចោលស្របតាមច្បាប់

(២) មិនទាន់ទទួលបាន ឬឆ្លងកាត់ការត្រួតពិនិត្យបច្ចេកទេសសុវត្ថិភាពលើយានយន្តជាទៀងទាត់។

យានយន្ត÷ សំដៅដល់យានដែលធ្វើចរាចរណ៍ដោយម៉ាស៊ីនលើផ្លូវគោក និងផ្លូវទឹក។

ការជ្រមុជទឹក÷ សំដៅលើសកម្មភាពក្រោមទឹកនៅក្នុងទន្លេ បឹង សមុទ្រ អាងស្តុកទឹក ប្រឡាយ និងតំបន់ទឹកផ្សេងៗទៀតដោយប្រើឧបករណ៍ជំនួយដកដង្ហើម។

ការឡើងភ្នំ÷ សំដៅលើសកម្មភាពនៃការឡើងភ្នំច្រាំងថ្ម ការសាងសង់ភ្នំ ច្រាំងថ្មចោទដែលមនុស្សបង្កើត ជ្រោះទឹកកក និងភ្នំទឹកកក។

ការផ្សងព្រេង÷ សំដៅទៅលើការដាក់ខ្លួនដោយចេតនាទៅក្នុងកាលៈទេសៈណាមួយដោយដឹងថាវាអាចបង្កឲ្យមានហានិភ័យដល់បាត់បង់ជីវិត ឬរងរបួសនៅក្រោមលក្ខខណ្ឌធម្មជាតិជាក់លាក់។ ឧទាហរណ៍÷ ការបណ្តែតខ្លួនតាមដងទន្លេ ការឡើងភ្នំ ការដើរតាមវាលខ្សាច់ ឬព្រៃស្រោងដែលមិនអាចចូលទៅដល់បាន។

ការសម្តែងជំនាញពិសេស÷ សំដៅទៅលើការសម្តែងនៃការជិះសេះ ការលេងសៀក ការបង្ហឹកសត្វ និងសកម្មភាពផ្សេងៗទៀត។

ជំងឺសតិអារម្មណ៍ និងអាកប្បកិរិយាមិនប្រក្រតី÷ ផ្អែកលើ "ចំណាត់ថ្នាក់ស្ថិតិអន្តរជាតិនៃជំងឺ និងបញ្ហាសុខភាពដែលពាក់ព័ន្ធ (ICD-10)" ចេញដោយអង្គការសុខភាពពិភពលោក។

សង្គ្រាម÷ សំដៅទៅលើការតស៊ូប្រដាប់អាវុធរវាងរដ្ឋ និងរដ្ឋ ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬក្រុមនយោបាយ និងក្រុមនយោបាយ សម្រាប់គោលបំណងនយោបាយ និងសេដ្ឋកិច្ច ដោយផ្អែកលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល។

<u>ការប៉ះទង្គិចផ្នែកយោធា</u>÷ សំដៅលើការប្រឈមមុខប្រដាប់អាវុធដាក់គ្នារវាងរដ្ឋ និងប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងវិសាលភាពជាក់លាក់ និងដោយផ្អែកលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល។

<u>ការបះបោរ</u>÷ សំដៅលើការរំខានប្រដាប់អាវុធ ដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមដោយផ្អែកលើសេចក្តីប្រកាសរបស់រដ្ឋាភិបាល។

<u>ការងារដែលមានហានិភ័យខ្ពស់</u>÷ សំដៅទៅលើកម្មករកាប់ព្រៃ អ្នកការពារភ្លើងឆេះព្រៃ អ្នកបង្កាត់ពូជសត្វចតុប្បាទ អ្នកបង្កាត់សត្វមានពិស អ្នកនេសាទនៅសមុទ្រ កម្មកររុករករ៉ែថ្មឬកម្មកររុករករ៉ែខ្សាច់ កម្មករធ្វើការក្នុងវិស័យរ៉ែ កម្មករប្រេងទាំងអស់នៅសមុទ្រ អ្នកមុជទឹក អ្នកបើកបររ៉ឺម៉កដោយប្រើម៉ាស៊ីន និងកម្មករធ្វើការតាមកន្លែង ក្រុមជួយសង្គ្រោះ អ្នកបើកឧទ្ធម្ភាគចក្រ កម្មករគ្រោងដែកថែប (កម្មករបង្ហាប់) កម្មករធ្វើរន្ទា អ្នកតំឡើងជញ្ជាំងកញ្ចក់មានរាំងនន សេវាបោសជូតសម្អាតផ្នែកខាងក្រៅនៃអគារខ្ពស់ៗ កម្មករសាងសង់ផ្លូវរូងក្រោមដី កម្មករសាងសង់ស្ពាន កម្មករសាងសង់គម្រោងទំនប់ធំ កម្មករជីកអណ្តូង បុគ្គលិកផ្នែកបំផ្ទុះ កម្មករផលិតប្រេងរាវ និងឧស្ម័ន ដូចជាឧស្ម័នធម្មជាតិ ធ្យូងថ្មទៅឧស្ម័ន កម្មករកែច្នៃគ្រឿងផ្ទុះ កាំជ្រួច និងជាតិផ្ទុះ កម្មករផលិតអាស៊ីត និងបាសខ្លាំង កម្មករកែច្នៃផលិតផលមានជាតិពុល កម្មកររុះរើនាវា អ្នកឆ្លើយឆ្លងក្នុងសង្គ្រាម អ្នកតំឡើងផ្ទាំងប៉ាណូពាណិជ្ជកម្មឬកម្មករសាងសងនៅលើអាគារខ្ពស់ៗ អ្នកសម្តែងជិះនួស អ្នកសម្តែងលើអាកាស អ្នកតំឡើង អ្នកជួសជុលគ្រឿងបរិក្ខារអគ្គិសនីដែលមានតង់ស្យុងខ្ពស់ បុគ្គលិកទទួលបន្ទុកបោះចោលកាកសំណល់គ្រោះថ្នាក់មានជាតិពុល និងវិទ្យុសកម្ម បុគ្គលដែលគ្មានការងាររយៈពេលវែង ប៉ូលីសផ្នែកអនុវត្តច្បាប់គ្រឿងញៀន ប៉ូលីសផ្នែកការពារកុប្បកម្ម ប៉ូលីសពិសេស អ្នកសង្គ្រោះបន្ទាន់ កងទ័ពពិសេស កងទ័ពអាកាស កងទ័ពនាវា និងថ្មើរជើង អ្នកលេងកីឡាជិះស្គី អ្នកប្រដាល់ឬកីឡាករប្រដាល់។ល។

**ប្រការ ២៤.- តារាងឧបសម្ព័ន្ធ ១ ២ ៣ និង៤**

**តារាងឧបសម្ព័ន្ធ ១ “តារាងអត្រាបុព្វលាភ”**

**(សម្រាប់ទឹកប្រាក់ត្រូវបានធានាចំនួន ១០០០ដុល្លារសហរដ្ឋអាមេរិក)**

រូបិយបណ្ណ÷ ដុល្លារសហរដ្ឋអាមេរិក

| អាយុ/ រយៈពេលបង់បុព្វលាភ | ការបង់បុព្វលាភ រយៈពេល ៥ឆ្នាំ | | ការបង់បុព្វលាភ រយៈពេល ១០ឆ្នាំ | | ការបង់បុព្វលាភ រយៈពេល ១៥ឆ្នាំ | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| 18 | 165.97 | 164.24 | 89.97 | 88.96 | 64.94 | 64.17 |
| 19 | 170.51 | 168.79 | 92.43 | 91.42 | 66.73 | 65.96 |
| 20 | 175.18 | 173.46 | 94.98 | 93.97 | 68.57 | 67.80 |

| | | | | | | |
|---|---|---|---|---|---|---|
| 21 | 179.99 | 178.28 | 97.59 | 96.59 | 70.46 | 69.71 |
| 22 | 184.94 | 183.24 | 100.29 | 99.29 | 72.41 | 71.67 |
| 23 | 190.04 | 188.34 | 103.06 | 102.07 | 74.43 | 73.70 |
| 24 | 195.29 | 193.59 | 105.91 | 104.93 | 76.50 | 75.79 |
| 25 | 200.70 | 198.99 | 108.86 | 107.88 | 78.64 | 77.94 |
| 26 | 206.27 | 204.55 | 111.89 | 110.92 | 80.85 | 80.16 |
| 27 | 212.00 | 210.26 | 115.01 | 114.05 | 83.14 | 82.46 |
| 28 | 217.91 | 216.15 | 118.24 | 117.28 | 85.50 | 84.83 |
| 29 | 223.99 | 222.18 | 121.56 | 120.59 | 87.94 | 87.27 |
| 30 | 230.26 | 228.40 | 125.00 | 124.01 | 90.48 | 89.80 |
| 31 | 236.72 | 234.79 | 128.55 | 127.53 | 93.10 | 92.41 |
| 32 | 243.37 | 241.35 | 132.22 | 131.16 | 95.82 | 95.10 |
| 33 | 250.23 | 248.09 | 136.01 | 134.90 | 98.64 | 97.88 |
| 34 | 257.29 | 255.02 | 139.93 | 138.75 | 101.57 | 100.76 |
| 35 | 264.56 | 262.13 | 143.98 | 142.72 | 104.61 | 103.72 |
| 36 | 272.04 | 269.44 | 148.16 | 146.81 | 107.75 | 106.79 |
| 37 | 279.73 | 276.94 | 152.47 | 151.01 | 111.02 | 109.95 |
| 38 | 287.64 | 284.65 | 156.92 | 155.35 | 114.41 | 113.21 |
| 39 | 295.77 | 292.53 | 161.53 | 159.78 | 117.93 | 116.55 |
| 40 | 304.13 | 300.63 | 166.29 | 164.36 | 121.59 | 120.01 |
| 41 | 312.72 | 308.94 | 171.20 | 169.06 | 125.40 | 123.57 |
| 42 | 321.55 | 317.46 | 176.28 | 173.90 | 129.35 | 127.23 |
| 43 | 330.61 | 326.20 | 181.52 | 178.86 | 133.47 | 131.01 |
| 44 | 339.92 | 335.16 | 186.94 | 183.96 | 137.74 | 134.89 |
| 45 | 349.47 | 344.35 | 192.54 | 189.19 | 142.19 | 138.89 |
| 46 | 359.28 | 353.77 | 198.32 | 194.57 | - | - |
| 47 | 369.34 | 363.44 | 204.30 | 200.11 | - | - |
| 48 | 379.68 | 373.40 | 210.49 | 205.83 | - | - |
| 49 | 390.30 | 383.65 | 216.91 | 211.74 | - | - |
| 50 | 401.22 | 394.22 | 223.56 | 217.84 | - | - |
| 51 | 412.46 | 405.11 | - | - | - | - |
| 52 | 424.06 | 416.32 | - | - | - | - |
| 53 | 436.02 | 427.89 | - | - | - | - |
| 54 | 448.30 | 439.83 | - | - | - | - |
| 55 | 460.98 | 452.18 | - | - | - | - |

| អាយុ/ រយៈពេលបង់បុព្វលាភ | ការបង់បុព្វលាភ រយៈពេល ២០ឆ្នាំ | | ការបង់បុព្វលាភ រយៈពេល ២៥ឆ្នាំ | | ការបង់បុព្វលាភ រយៈពេល ៣០ឆ្នាំ | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| 18 | 52.48 | 51.84 | 45.08 | 44.53 | 40.46 | 39.96 |
| 19 | 53.93 | 53.30 | 46.34 | 45.80 | 41.60 | 41.12 |
| 20 | 55.43 | 54.80 | 47.64 | 47.11 | 42.79 | 42.32 |
| 21 | 56.97 | 56.36 | 48.98 | 48.46 | 44.02 | 43.56 |

| | | | | | | |
|---|---|---|---|---|---|---|
| 22 | 58.57 | 57.97 | 50.37 | 49.87 | 45.30 | 44.85 |
| 23 | 60.21 | 59.63 | 51.81 | 51.32 | 46.63 | 46.18 |
| 24 | 61.91 | 61.34 | 53.30 | 52.83 | 48.00 | 47.57 |
| 25 | 63.67 | 63.11 | 54.85 | 54.39 | 49.44 | 49.00 |
| 26 | 65.49 | 64.95 | 56.45 | 56.00 | 50.93 | 50.49 |
| 27 | 67.37 | 66.84 | 58.12 | 57.67 | 52.49 | 52.04 |
| 28 | 69.33 | 68.81 | 59.86 | 59.41 | 54.12 | 53.64 |
| 29 | 71.35 | 70.84 | 61.67 | 61.20 | 55.83 | 55.31 |
| 30 | 73.46 | 72.94 | 63.56 | 63.07 | 57.62 | 57.04 |
| 31 | 75.66 | 75.11 | 65.53 | 65.00 | - | - |
| 32 | 77.94 | 77.36 | 67.59 | 67.00 | - | - |
| 33 | 80.32 | 79.69 | 69.75 | 69.08 | - | - |
| 34 | 82.80 | 82.10 | 72.01 | 71.23 | - | - |
| 35 | 85.38 | 84.59 | 74.38 | 73.47 | - | - |
| 36 | 88.08 | 87.17 | - | - | - | - |
| 37 | 90.88 | 89.83 | - | - | - | - |
| 38 | 93.81 | 92.59 | - | - | - | - |
| 39 | 96.88 | 95.42 | - | - | - | - |
| 40 | 100.08 | 98.36 | - | - | - | - |

បញ្ជាក់÷ ការបង់បុព្វលាភប្រចាំឆមាស = យោងតាមការបង់បុព្វលាភប្រចាំឆ្នាំ x 0.52

ការបង់បុព្វលាភប្រចាំត្រីមាស = យោងតាមការបង់បុព្វលាភប្រចាំឆ្នាំ x 0.27

ការបង់បុព្វលាភប្រចាំខែ = យោងតាមការបង់បុព្វលាភប្រចាំឆ្នាំ x 0.09

## តារាងឧបសម្ព័ន្ធ ២ "តារាងពិការភាពជាអចិន្ត្រៃយ៍នៃធានារ៉ាប់រងបុគ្គល"

| ប្រភេទ | ចំនួន | ការពណ៌នាពីពិការភាព |
|---|---|---|
| ពិការភាពជាអចិន្ត្រៃយ៍ | 1 | ការបាត់បង់ទាំងស្រុង និងជាអចិន្ត្រៃយ៍នៃចក្ខុវិញ្ញាណរបស់ភ្នែកទាំងពីរ (ចំណាំទី ១) |
| | 2 | ការបាត់បង់អវយវៈខាងលើពីរ ឬអវយវៈខាងក្រោមពីរ |
| | 3 | ការបាត់បង់អវយវៈខាងលើមួយ និងអវយវៈខាងក្រោមមួយ |
| | 4 | ការបាត់បង់ទាំងស្រុង និងជាអចិន្ត្រៃយ៍នូវចក្ខុវិញ្ញាណរបស់ភ្នែកម្ខាង និងការបាត់បង់អវយវៈផ្នែកខាងលើមួយ |
| | 5 | ការបាត់បង់ទាំងស្រុង និងជាអចិន្ត្រៃយ៍នូវចក្ខុវិញ្ញាណរបស់ភ្នែកម្ខាង និងការបាត់បង់អវយវៈផ្នែកខាងក្រោមមួយ |
| | 6 | ការបាត់បង់មុខងារទាំងស្រុង និងជាអចិន្ត្រៃយ៍នូវអវយវៈចំនួនបួន (ចំណាំទី ២) |
| | 7 | ការបាត់បង់ទាំងស្រុង និងជាអចិន្ត្រៃយ៍នូវមុខងារនៃការទំពារ និងការលេប (ចំណាំទី ៣) |

| | | |
|---|---|---|
| | ៨ | ប្រព័ន្ធសរសៃប្រសាទកណ្តាល ឬបញ្ហាទ្រូង ឬជំងឺពោះវៀនធំ [ដែលបណ្តាលឲ្យ] អលទ្ធភាពធ្វើការងារណាមួយពេញមួយជីវិត និងត្រូវការជំនួយពីអ្នកដទៃសម្រាប់សកម្មភាពប្រចាំថ្ងៃដើម្បីទ្រទ្រង់ជីវិត (ចំណាំទី ៤) |

**ចំណាំ÷**

(1) ការបាត់បង់ចក្ខុវិញ្ញាណ រួមមានការបាត់បង់ ឬការបាត់បង់គ្រាប់ភ្នែក ឬការមិនអាចបែងចែកបានរវាងភាពភ្លឺ និងភាពងងឹត ឬគ្រាន់តែអាចកំណត់បាននៅពេលដែលដៃធ្វើសកម្មភាពនៅពីមុខភ្នែក។ កែវយឹតដែលត្រឹមត្រូវបំផុត គឺទាបជាង ០.០២ នៃស្តង់ដារចក្ខុវិស័យអន្តរជាតិ ឬកាំរស្មីតិចជាង៥ដឺក្រេ និងមានវិញ្ញាបនប័ត្របញ្ជាក់ពីរោគវិនិច្ឆ័យដែលចេញដោយអ្នកឯកទេសជំនាញផ្នែកភ្នែកដែលត្រូវបានទទួលស្គាល់ដោយក្រុមហ៊ុនធានារ៉ាប់រង។

(2) ការបាត់បង់មុខងារនៃអវយវៈ មានន័យថាជាការរឹងជាអចិន្ត្រៃយ៍ ឬខ្វិន ឬអសមត្ថភាពដើម្បីផ្លាស់ទីដោយសេរីនៃអវយវៈ។

(3) ការបាត់បង់មុខងារទាំងស្រុង និងជាអចិន្ត្រៃយ៍នៃការទំពារ និងការលេប សំដៅទៅលើស្ថានភាពនៃបញ្ហារាងកាយ ឬបញ្ហាខុសធម្មតា ដែលបណ្តាលមកពីហេតុផលណាមួយក្រៅពីធ្មេញ ដែលបណ្តាលឲ្យអសមត្ថភាពក្នុងការទំពារ ឬលេប និងអសមត្ថភាពក្នុងការញ៉ាំ ឬលេបអាហារណាមួយក្រៅពីវត្ថុរាវ។

(4) ត្រូវការជំនួយពីអ្នកដទៃសម្រាប់សកម្មភាពប្រចាំថ្ងៃដើម្បីទ្រទ្រង់ជីវិត សំដៅទៅលើភាពអសមត្ថភាពក្នុងការញ៉ាំ ការបញ្ចេញចោល ការស្លៀកពាក់ ការដោះសំលៀកបំពាក់ ការរស់នៅ ការដើរហើរ ការងូតទឹកដោយខ្លួនឯងជាដើម និងត្រូវការជំនួយពីអ្នកដទៃ។

**តារាងឧបសម្ព័ន្ធ ៣÷ "៣៨ ប្រភេទនៃជំងឺធ្ងន់ធ្ងរ"**

| វាយឈ្មោះ | ឈ្មោះជំងឺ | និយមន័យជំងឺ |
|---|---|---|
| ១<br>……<br>១៦ | មហារីកសួត<br>(Lung Cancer)<br>មហារីកថ្លើម<br>(Liver Cancer)<br>មហារីកក្រពះ<br>(Stomach Cancer)<br>មហារីកពោះវៀនធំ<br>(Colorectal Cancer) | សំដៅលើជំងឺដែលកោសិកាកាចសាហាវបន្តវិវត្ត រាលដាល វាយលុក និងបំផ្លាញជាលិកាធម្មតានៅជុំវិញវា ដោយមិនអាចគ្រប់គ្រងបាន។ វាអាចប្តូរទីទៅផ្នែកដទៃទៀតនៃរាងកាយតាមសរសៃឈាម សរសៃឡាំហ្វាទិក និងទីចំហនៅក្នុងដងខ្លួន។ ក្រោយការធ្វើរោគវិនិច្ឆ័យ pathological diagnosis និង clinical diagnosis ដុំសាច់កាចសាហាវ ស្ថិតនៅក្នុងប្រភេទក្រោម "ការធ្វើចំណាត់ថ្នាក់ស្ថិតិអន្តរជាតិនៃជំងឺ និងបញ្ហាសុខភាពដែលពាក់ព័ន្ធ" (ICD-10) នៃអង្គការសុខភាពពិភពលោក។ |

| | | |
|---|---|---|
| | មហារីកក្រពេញប្រូស្តាត (Prostate Cancer)<br>មហារីកតម្រងនោម (Kidney Cancer)<br>មហារីកកូនកណ្តុរ (Lymphoma)<br>មហារីកប្លោកនោម (Bladder Cancer)<br>មហារីកគ្រាប់ឈាម (Leukemia)<br>មហារីកខួរក្បាល (Brain Cancer)<br>មហារីកលំពែង (Pancreatic Cancer)<br>មហារីកក្រពេញទីរ៉ូអ៊ីត (Thyroid Cancer)<br>មហារីកអូវែរ (Ovarian Cancer)<br>មហារីកសុដន់ (Breast Cancer)<br>មហារីកមាត់ស្បូន (Cervical Cancer)<br>មហារីកស្បូន (Endometrial Cancer)<br>សរុបទាំងអស់មានជំងឺមហារីកចំនួន១៦ប្រភេទ<br>[ដុំសាច់កាចសាហាវ (Malignant neoplasms)] | ជំងឺដូចខាងក្រោមនេះមិនត្រូវបានដាក់បញ្ចូលទេ÷<br>i. ជំងឺមហារីកនៅនឹងកន្លែង<br>ii. ជំងឺមហារីកគ្រាប់ឈាម និងខួរឆ្អឹងរ៉ាំរ៉ៃ (CLL) នៅដំណាក់កាលទី ១ នៃប្រព័ន្ធ Binet។<br>iii. ជំងឺ Hodgkin នៅដំណាក់កាលទី ១នៃប្រព័ន្ធកំណត់ដំណាក់កាល Ann Arbor<br>iv. មហារីកស្បែក (មិនរាប់បញ្ចូលមហារីកស្បែក melanoma និង មហារីកស្បែក metastatic) ។<br>v. មហារីកប្រូស្តាតនៅដំណាក់កាល T 1 N 0 M 0 នៃប្រព័ន្ធកំណត់ដំនាក់កាល TNM ។ |
| ១៧ | ការវះកាត់ផ្លាស់ប្តូរសរីរាង្គសំខាន់ ឬប្រតិបត្តិការប្តូរកោសិកាឈាម (Major organ transplant or hematopoietic stem cell transplant operation) | ការវះកាត់ផ្លាស់ប្តូរសរីរាង្គសំខាន់ សំដៅទៅ [លក្ខខណ្ឌមួយដែល] ការលាងសម្អាតតម្រងនោម ថ្លើម បេះដូង ឬសួតត្រូវបានអនុវត្តដោយសារតែសរីរៈដែលពាក់ព័ន្ធមិនដំណើរការ។ ដំណើរការប្តូរកោសិកាឈាមសំដៅទៅលើ [ស្ថានភាពមួយដែល] ការលាងសម្អាតកោសិកាឈាម (រាប់បញ្ចូលទាំងកោសិកាឈាម hematopoietic ខួរឆ្អឹង កោសិកាឈាម hematopoietic និងកោសិកាឈាមដើម hematopoietic នៅក្រៅសរសៃវិញ្ញាណខួរឆ្អឹង) ដោយសារតែដំណើរការមិនប្រក្រតីនៃឈាម ឬ ជំងឺឈាមឈាមកាចសាហាវ។ |

| | | |
|---|---|---|
| ១៨ | ដំណាក់កាលចុងក្រោយនៃជំងឺតម្រងនោម (ដែលគេហៅថារោគបំពង់ទឹកនោមរ៉ាំរ៉ៃ) [Final stage of kidney disease (also called chronic renal failure uremia)] | សំដៅដល់ការខូចរ៉ាំរ៉ៃដែលមិនអាចជួសជុលបាន ដែលឈានដល់ដំណាក់កាលជំងឺបំពង់ទឹកនោម ហើយបន្ទាប់ពីការធ្វើរោគវិនិច្ឆ័យ បានឆ្លងកាត់យ៉ាងហោចណាស់៩០ថ្ងៃនៃការព្យាបាលដោយការលាងឈាមធម្មតា ឬការប្តូរតម្រងនោម។ |
| ១៩ | ជំងឺរលាកថ្លើមធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរ និងស្រួចស្រាវ (Acute or acute and malignant severe hepatitis) | សំដៅដល់ [លក្ខខណ្ឌមួយ] នៃការរីសាយភាយជាលិកាងាប់របស់ថ្លើម ដោយសារការឆ្លងមេរោគរលាកថ្លើមដែលបណ្តាលអោយមានជំងឺថ្លើមស្រួចស្រាវ និងត្រូវបានបញ្ជាក់ដោយការវិភាគឈាមរកវត្តមានមេរោគ ឬការពិនិត្យវិសាណូសាស្ត្រ ដែលអាចមានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷<br>1. ជំងឺខាន់លឿងធ្ងន់ធ្ងរ ឬជំងឺខាន់លឿងកំពុងកើតមានឡើងយ៉ាងឆាប់រហ័ស។<br>2. ជំងឺប្រព័ន្ធប្រសាទបង្កដោយជំងឺថ្លើម<br>3. ទំហំថ្លើមត្រូវបានបង្ហាញដោយការថតអេកូសាស្ត្រB ឬការសិក្សាតាមរូបភាពដទៃទៀត និងកាន់តែរួមតូចយ៉ាងឆាប់រហ័ស។<br>4. សន្ទស្សន៍មុខងារថ្លើមថយចុះជាលំដាប់។ |
| ២០ | ដុំសាច់ក្នុងខួរក្បាលប្រភេទស្រាល (Benign brain neoplasms) | សំដៅទៅលើ [ស្ថានភាពមួយ] ដែលដុំសាច់ក្នុងខួរក្បាលប្រភេទស្រាល បង្កឱ្យមានការកើនឡើងនៃសម្ពាធក្នុងសរសៃឈាម ហើយការបង្ហាញរោគសញ្ញាហើមខួរក្បាល រោគសញ្ញាវិកលចរិក ជំងឺឆ្កួតជ្រូក/ស្កន់ និងរោគសញ្ញាផ្លូវចិត្តដែលជាការគំរាមកំហែងដល់អាយុជីវិត។ វាត្រូវតែការការបញ្ជាក់ដោយការវិភាគវិទ្យុឆាយាកម្ម ដូចជា ការថតក្បាល (CT) ការថតដោយប្រើរំញ័រម៉ាញ៉េទិក (MRI) ឬការថតវិមាត្របញ្ចេញប៉ូស៊ីត្រុន (PET) ហើយយ៉ាងហោចណាស់ ត្រូវតែបំពេញតាមលក្ខខណ្ឌមួយក្នុង ចំណោមលក្ខខណ្ឌដូចខាងក្រោម÷<br>1. ការវះកាត់លលាដ៏ក្បាលពិតជាត្រូវបានធ្វើឡើងដើម្បីយកដុំសាច់ក្នុងខួរក្បាលទាំងអស់ ឬផ្នែកនៃដុំសាច់ចេញ<br>2. ការព្យាបាលដោយកាំរស្មីត្រូវបានអនុវត្តចំពោះដុំសាច់ក្នុងខួរក្បាល។ ដុំសាច់ក្នុងក្រពេញខាងក្រោមខួរក្បាល ពកសាច់ខួរក្បាល និងជំងឺសរសៃឈាមក្នុងខួរក្បាល មិនត្រូវបានរួមបញ្ចូលទេ។ |
| ២១ | ដំណាក់កាលធ្ងន់នៃការខូចថ្លើមរ៉ាំរ៉ៃ (Decompensation stage of chronic liver failure) | សំដៅទៅលើការខូចថ្លើមដោយសារជំងឺថ្លើមរ៉ាំរ៉ៃ ដែលអាចមានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷<br>1. ជំងឺខាន់លឿងរ៉ាំរ៉ៃ<br>2. ទាចទឹក |

| | | |
|---|---|---|
| | | 3. ជំងឺប្រព័ន្ធប្រសាទបង្កដោយជំងឺថ្លើម<br>4. ជំងឺហើមស្លាក់អណ្តើកក្រពះ ដោយមានជំងឺអណ្តើកក្រពះបំផ្លាញគ្រាប់ឈាម ឬការឡើងរឹងប៉ោងនៃសរសៃឈាមនៅក្នុងបំពង់អាហារ។<br>ជំងឺខូចថ្លើមដោយសារតែការផឹកស្រា ឬប្រើថ្នាំពេទ្យ មិនត្រូវបានរាប់បញ្ចូលនោះទេ។ |
| ២២ | ផលវិបាកក្រោយជំងឺរលាកខួរក្បាល ឬជំងឺរលាកស្រោមខួរ<br>(Sequela of encephalitis or meningitis) | សំដៅទៅការខូចជាអចិន្ត្រៃយ៍នៃប្រព័ន្ធប្រសាទដោយសារជំងឺរលាកខួរក្បាល ឬរលាកស្រោមខួរ។ ការខូចជាអចិន្ត្រៃយ៍នៃមុខងារប្រព័ន្ធប្រសាទមានន័យថាមានជំងឺមួយ ឬច្រើនដូចខាងក្រោម ក្រោយពីរយៈពេល ១៨០ ថ្ងៃនៃការធ្វើរោគវិនិច្ឆ័យ÷<br>1. ការបាត់បង់ទាំងស្រុងនៃមុខងារអវយវៈមួយ ឬច្រើន(កំណត់សម្គាល់ ១)<br>2. ការបាត់បង់ទាំងស្រុងនៃមុខងារក្នុងការនិយាយ ឬមុខងារទំពារ និងលេប (កំណត់សម្គាល់ ២)<br>3. ការបាត់បង់ទាំងស្រុងនូវសមត្ថភាពរស់នៅដោយឯករាជ្យ និងការបាត់បង់សមត្ថភាពអនុវត្តសកម្មភាពប្រចាំថ្ងៃ បីឬច្រើនជាងនេះក្នុងចំនោមសកម្មភាពមូលដ្ឋានប្រចាំថ្ងៃទាំង ៦ (កំណត់សម្គាល់ ៣)។ |
| ២៣ | ការសន្លប់ឈឺង<br>(Deep coma) | សំដៅដល់ការបាត់បង់ស្មារតីដោយសារជំងឺ ឬរបួស ពុំមានប្រតិកម្មតបទៅនឹងការជំរុញខាងក្រៅ និងតម្រូវការខាងក្នុង ដែលការសន្លប់មានកម្រិត ៥ ឬទាបជាង ៥ ក្នុងរង្វាស់ការសន្លប់ Glasgow ហើយត្រូវបន្តប្រើប្រព័ន្ធដង្ហើមនិងប្រព័ន្ធទ្រទ្រង់ជីវិតផ្សេងៗទៀត ក្នុងរយៈពេលច្រើនជាង៩៦ម៉ោង។<br>ការសន្លប់ឈឺងដែលបណ្តាលមកពីការប្រើគ្រឿងស្រវឹង ឬថ្នាំពេទ្យ មិនត្រូវបានរាប់បញ្ចូលនោះទេ។ |
| ២៤ | ការបាត់បង់សោតវិញ្ញាណទាំងពីរ<br>(Binaural hearing loss) | សំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍នៃ និងមិនអាចស្រោចស្រង់បាននូវសមត្ថភាពស្តាប់ទាំងពីរ ដោយសារតែជំងឺ ឬការរងរបួស។ កម្រិតនៃសមត្ថភាពស្តាប់ជាមធ្យមគឺខ្ពស់ជាង 90 dB នៅប្រេកង់ 500 Hz, 1000 Hz និង 2000 Hz ដែលអាចត្រូវបានបញ្ជាក់ដោយការធ្វើតេស្តសំឡេងសុទ្ធ ការបញ្ជូនសំឡេង ឬការធ្វើតេស្តរំញោចសក្តានុពលសោតវិញ្ញាណ។ |
| ២៥ | ជំងឺគ្មានចលនា<br>(Paralysis) | សំដៅទៅការបាត់បង់មុខងារអចិន្ត្រៃយ៍ និងទាំងស្រុងនៃអវយវៈពីរ ឬច្រើនដោយសារតែជំងឺ ឬគ្រោះថ្នាក់។ អចិន្ត្រៃយ៍ និងទាំងស្រុង សំដៅទៅលើ [លក្ខខណ្ឌដែល] សន្លាក់ ២ ចំណោមសន្លាក់សំខាន់ៗទាំង ៣ នៃអវយវៈនីមួយៗ នៅតែរឹង ឬមិនអាចធ្វើចលនាបាន បន្ទាប់ពីរយៈពេល ១៨០ថ្ងៃនៃការធ្វើរោគវិនិច្ឆ័យនៃជំងឺ ឬ ១៨០ថ្ងៃបន្ទាប់ពីការកើតឡើងនៃគ្រោះថ្នាក់។ |

| | | |
|---|---|---|
| ២៦ | វះកាត់សន្ទះបេះដូង<br>(Heart valve surgery) | សំដៅទៅលើ [ស្ថានភាពមួយដែល] ការវះកាត់ដូរសន្ទះបេះដូង ឬការវះកាត់ដើម្បីជួសជុល ត្រូវបានអនុវត្តសម្រាប់ការព្យាបាលនៃជំងឺសន្ទះបេះដូង។ |
| ២៧ | ជំងឺខូចខួរក្បាលធ្ងន់ធ្ងរ<br>(Severe brain damage) | សំដៅទៅលើ [ស្ថានភាពមួយដែល] ដំបន់ខួរក្បាលសំខាន់ត្រូវបានរងរបួសដោយសារតែកម្លាំងខាងក្រៅប៉ះទង្គិចនឹងក្បាល ដែលនាំឲ្យខូចជាអចិន្ត្រៃយ៍នៃមុខងារប្រព័ន្ធប្រសាទ ដែលអាចត្រូវបានបញ្ជាក់ដោយការថតក្បាល (CT) ការថតដោយប្រើរំញ័រម៉ាញ៉េទិក (MRI) ឬការថតវិមាត្របញ្ចេញប៉ូស៊ីត្រុន (PET)។ ការខូចមុខងារអចិន្ត្រៃយ៍នៃប្រព័ន្ធប្រសាទមានន័យថាបន្ទាប់ពី ១៨០ថ្ងៃនៃរបួសខួរក្បាល មុខងារមួយ ឬច្រើននៃមុខងារខាងក្រោមបន្តមិនដំណើរការ÷<br>1. ការបាត់បង់ទាំងស្រុងនៃមុខងារអវយវៈមួយ ឬច្រើន (កំណត់សម្គាល់ ១)<br>2. ការបាត់បង់ទាំងស្រុងនៃមុខងារក្នុងការនិយាយ ឬមុខងារទំពារ និងលេប (កំណត់សម្គាល់ ២)<br>3. ការបាត់បង់ទាំងស្រុងនូវសមត្ថភាពរស់នៅឯករាជ្យ និងអសមត្ថភាពក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ បី ឬច្រើនជាងនេះ ក្នុងចំណោមសកម្មភាពមូលដ្ឋានប្រចាំថ្ងៃទាំង ៦ (កំណត់សម្គាល់ ៣)។ |
| ២៨ | ការរលាកកម្រិតទី ៣ ធ្ងន់ធ្ងរ<br>(Severe third-degree burns) | សំដៅទៅកម្រិតនៃការរលាកនៅកម្រិតទី ៣ ហើយតំបន់ដែលរលាកនៅកម្រិតទី ៣ នោះ គ្របបណ្តប់ដល់ទៅ ២០% នៃរាងកាយទាំងមូល ឬច្រើនជាងនេះ។ |
| ២៩ | សម្ពាធឈាមខ្ពស់ក្នុងសរសៃឈាមដែលផ្តល់ឲ្យសួត<br>(Severe primary pulmonary hypertension) | សំដៅទៅលើ [លក្ខខណ្ឌដែល] មិនអាចពន្យល់បាន ដែលសម្ពាធក្នុងសរសៃឈាមសួតបន្តកើនឡើង និងវិវត្តនាំឲ្យមានជំងឺរ៉ាំរ៉ៃដែលបណ្តាលឲ្យមានកង្វះសមត្ថភាពជាអចិន្ត្រៃយ៍ និងមិនកែបាន ក្នុងការធ្វើលំហាត់ប្រាណ និងបានឈានដល់ចំណាត់ថ្នាក់ទី ៤ នៃការធ្វើចំណាត់ថ្នាក់មុខងាររបស់សមាគមបេះដូងទីក្រុងញូវយ៉ក (NYHA) ហើយសម្ពាធសរសៃឈាមសួតមធ្យមលើសពី 30mmHg នៅពេលសម្រាក។ |
| ៣០ | ជំងឺកោសិកាប្រសាទធ្ងន់ធ្ងរ<br>(Severe motor neuron disease) | គឺជាក្រុមមួយនៃជំងឺកោសិកាប្រសាទនៃប្រព័ន្ធប្រសាទមិនដំណើរការ រួមបញ្ចូលទាំងការស្វិតទ្រោមជាបន្តបន្ទាប់នៃសាច់ដុំឆ្អឹងខ្នង ពិការភាពខួរឆ្អឹងខ្នង ជំងឺក្រិនកោសិកាសាច់ដុំខួរក្បាល ជំងឺក្រិនកោសិកាសាច់ដុំបញ្ចាចលនា ដែលអាចទទួលរងនូវការបាត់បង់ទាំងស្រុងនូវសមត្ថភាពរស់នៅឯករាជ្យ និងអសមត្ថភាពក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ បីឬច្រើនជាងនេះ ក្នុងចំណោមសកម្មភាពមូលដ្ឋានប្រចាំថ្ងៃទាំង ៦ (កំណត់សម្គាល់ ៣)។ |
| ៣១ | ការបាត់បង់សមត្ថភាពនិយាយ<br>(Loss of speech) | សំដៅដល់ការបាត់បង់សមត្ថភាពទាំងស្រុងក្នុងការនិយាយ ដោយសារតែជំងឺ ឬគ្រោះថ្នាក់ ហើយមិនអាចជាសះស្បើយដដោយការព្យាបាលដែលមានស្រាប់ ទោះបីជាទទួលបានការព្យាបាលយ៉ាងសកម្ម យ៉ាងហោចណាស់រយៈពេល ១២ |

| | | |
|---|---|---|
| | | ខែហើយក៏ដោយ (រយៈពេលនេះមិនអាចអនុវត្តបានដើម្បីបំបាត់ទាំងស្រុងនូវបំពង់សំឡេងនោះទេ) ។<br>ការបាត់បង់សមត្ថភាពនិយាយដោយកត្តាចិត្តសាស្ត្រ មិនត្រូវបានរាប់បញ្ចូលនោះទេ។ |
| ៣២ | ជំងឺខ្វះឈាមធ្ងន់ធ្ងរ<br>(Severe aplastic anemia) | សំដៅដល់កង្វះឈាមក្រហម កង្វះកោសិកាឈាមស និងជំងឺដែលមានប្លាកែតថយចុះ ដោយសារតែការខូចរ៉ាំរ៉ៃនៃមុខងារបង្កើតឈាមនៃខួរឆ្អឹង ដែលអាចមានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷<br>i. ការធ្វើរោគវិនិច្ឆ័យត្រូវបានគាំទ្រដោយលទ្ធផលនៃការច្រិបសាច់ខួរឆ្អឹង<br>ii. កោសិការគ្រាប់ឈាមបំពេញលក្ខខណ្ឌបីដូចខាងក្រោម÷<br>1. តម្លៃដាច់ខាតនៃនឺត្រូហ្វាល(កោសិកាឈាមសខ្ចី)≤0.5 Û $10^9$ / L<br>2. គោលិកាក្រហមថ្មីមានរាងដូចជាសំណាញ់ (Reticulocytes) <1%<br>3. តម្លៃដាច់ខាតនៃប្លាកែត ≤ 0.5 Û 10 9 / L។ |
| ៣៣ | ការវះកាត់សរសៃឈាមក្រហម<br>(Aorta surgery) | សំដៅទៅលើ [ស្ថានភាពនៃ] ការវះកាត់ទ្រូង ឬការវះកាត់នៅផ្នែកពោះ ដើម្បីយកចេញ ដាក់ជំនួស ឬជួសជុលសរសៃឈាមក្រហមដែលខូច ដើម្បីព្យាបាលជំងឺសរសៃឈាមក្រហម។ សរសៃឈាមក្រហមសំដៅទៅលើសរសៃឈាមក្រហមនៅផ្នែកទ្រូង និងពោះ ដោយមិនរាប់បញ្ចូលមែកធាងនៃសរសៃឈាមទ្រូង និងសរសៃឈាមពោះ។<br>ការវះកាត់ជួសជុលសរសៃឈាមដោយធ្វើតាមស្បែក មិនត្រូវបានរាប់បញ្ចូលនោះទេ។ |
| ៣៤ | ផលវិបាកក្រោយជំងឺពិការបញ្ញា<br>(Sequela of cerebral apoplexy) | សំដៅទៅលើការហូរឈាមខួរក្បាល ការស្ទះសរសៃឈាមដោយកំណកឈាម ឬការងាប់នៃជាលិកាដោយសារការផ្គត់ឈាមត្រូវកាត់ផ្តាច់ ដោយសារជំងឺសរសៃឈាមខួរក្បាលដែលបណ្តាលឲ្យមានជំងឺអចិន្ត្រៃយ៍នៃប្រព័ន្ធប្រសាទ។ ការខូចមុខងារអចិន្ត្រៃយ៍នៃប្រព័ន្ធប្រសាទមានន័យថាបន្ទាប់ពី ១៨០ថ្ងៃនៃរបួសខួរក្បាល មុខងារមួយ ឬច្រើននៃមុខងារខាងក្រោមបន្តមិនដំណើរការ÷<br>1. ការបាត់បង់ទាំងស្រុងនៃមុខងារអវយវៈមួយ ឬច្រើន(កំណត់សម្គាល់ ១)<br>2. ការបាត់បង់ទាំងស្រុងនៃមុខងារក្នុងការនិយាយ ឬមុខងារទំពារ និងលេប (កំណត់សម្គាល់ ២)<br>3. ការបាត់បង់ទាំងស្រុងនូវសមត្ថភាពរស់នៅឯករាជ្យ និងអសមត្ថភាពក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃបី ឬច្រើនជាងនេះ ក្នុងចំណោមសកម្មភាពមូលដ្ឋានប្រចាំថ្ងៃទាំង ៦ (កំណត់សម្គាល់ ៣)។ |

| | | |
|---|---|---|
| ៣៥ | ការងាប់ផ្នែករបស់សាច់ដុំបេះដូងស្រួចស្រាវ (Acute myocardial infarction) | សំដៅដល់ [លក្ខខណ្ឌមួយដែល] ការស្ទះសរសៃឈាមបេះដូងដែលបណ្តាលអោយការផ្គត់ផ្គង់ឈាមមិនគ្រប់គ្រាន់ ទៅតាមតំបន់ ហើយនាំឲ្យមានការរលាកសាច់ដុំបេះដូង ដែលអាចមានលក្ខខណ្ឌ ៣ ក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷<br>1. ការបង្ហាញរោគសញ្ញាជាទូទៅដូចជាឈឺដើមទ្រូងស្រួចស្រាវ<br>2. បង្ហាញដោយការផ្លាស់ប្តូរអេគ្គិសនីបេះដូងថ្មីៗ<br>3. អង់ស៊ីមសាច់ដុំបេះដូង ឬបណ្តុំប្រូតេអ៊ីនបេះដូង មានសារៈសំខាន់ផ្នែករោគវិនិច្ឆ័យ ឬត្រូវបានបង្ហាញថាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការប្រែប្រួលនៃការងាប់ផ្នែករបស់សាច់ដុំបេះដូងស្រួចស្រាវ<br>4. រយៈពេល ៩០ ថ្ងៃក្រោយពីធាតុបង្កជំងឺ បន្ទាប់ពីការវិភាគ នោះវាត្រូវបានបញ្ជាក់ថាមានការខូចមុខងារបេះដូងខាងឆ្វេង ឧទាហរណ៍÷ ការកណ្តោក់ចេញនៃថតបេះដូងខាងឆ្វេងមានតិចជាង ៥០%។ |
| ៣៦ | ជំងឺផាកឃីនសាន់ (Parkinson) ធ្ងន់ធ្ងរ | គឺជាជំងឺកោសិការប្រសាទនៃប្រព័ន្ធប្រសាទកណ្តាល។ ការបង្ហាញរោគសញ្ញារបស់វាគឺពិការភាព ជំងឺអាតាស៊ៀ។ ល។ ដែលអាចមានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷<br>1. ការព្យាបាលមិនអាចគ្រប់គ្រងស្ថានភាពជំងឺបានទេ<br>2. ការបាត់បង់ទាំងស្រុងនូវសមត្ថភាពរស់នៅឯករាជ្យ និងអសមត្ថភាពក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ បី ឬច្រើនជាងនេះ ក្នុងចំណោមសកម្មភាពមូលដ្ឋានប្រចាំថ្ងៃទាំង ៦ (កំណត់សម្គាល់ ៣)។<br>រោគសញ្ញាជំងឺផាកឃីនសាន់ ទី ២ មិនត្រូវបានរាប់បញ្ចូលនោះទេ។ |
| ៣៧ | ជំងឺអាល់ហៃ្សមឺរ (Alzheimer) ធ្ងន់ធ្ងរ | សំដៅលើជំងឺដែលការប្រែប្រួលខួរក្បាលដែលបន្ត និងមិនអាចស្រោចស្រង់បានបណ្តាលឲ្យមានការធ្លាក់ចុះ ឬការបាត់បង់សតិបញ្ញាធ្ងន់ធ្ងរ។ ការបង្ហាញរោគសញ្ញារបស់វាគឺការខូចមុខងារនៃការយល់ដឹងជាក់ស្តែង ភាពមិនប្រក្រតីនៃអាកប្បកិរិយា និងភាពចុះខ្សោយខាងផ្នែកសង្គម ហើយត្រូវការការគាំទ្រពីអ្នកដទៃសម្រាប់ការរស់នៅប្រចាំថ្ងៃ ដែលអាចត្រូវបានបញ្ជាក់ដោយការថតក្បាល (CT) ការថតដោយប្រើរំញ័រម៉ាញ៉េទិក (MRI) ឬការថតវិមាត្របញ្ចេញប៉ូស៊ីត្រុន (PET) និងការបាត់បង់ទាំងស្រុងនូវសមត្ថភាពរស់នៅឯករាជ្យ និងអសមត្ថភាពក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ បីឬច្រើនជាងនេះ ក្នុងចំណោមសកម្មភាពមូលដ្ឋានប្រចាំថ្ងៃទាំង ៦ (កំណត់សម្គាល់ ៣)។<br>ជំងឺសរសៃប្រសាទ និងជំងឺផ្លូវចិត្តមិនត្រូវបានរាប់បញ្ចូលនោះទេ។ |



អាគារកាណាឌីយ៉ាជាន់ទី26 CDEF វិថីព្រះអង្គឌួងលេខ315 ក្រុងភ្នំពេញ 26th Floor CDEF Canadia Tower 315 Ang Doung Street Phnom Penh Tel: 023989218

| | | |
|---|---|---|
| ៣៨ | ការវះកាត់ព្យាបាលសរសៃឈាម (Coronary artery bypass grafting) | សំដៅទៅលើ [ស្ថានភាពមួយដែល] ការវះកាត់ទ្រូងដែលត្រូវបានអនុវត្ត ដើម្បីប្តូរសរសៃឈាម សម្រាប់ព្យាបាលជំងឺសរសៃឈាមបេះដូងធ្ងន់ធ្ងរ។ ការចាក់បញ្ចូលសរសៃឈាមបេះដូងសរសៃឈាមខួរក្បាល ឆ្អឹងខ្នងបេះដូងបច្ចេកវិទ្យាឡាស៊ែរ និងវិធីវះកាត់ខុសពីធម្មតាដទៃទៀត និងការវះកាត់តាមបែបផ្លុះមិនត្រូវបានគ្របដណ្តប់នោះទេ។ |

**ចំណាំ÷**

(1) ការបាត់បង់មុខងារនៃអវយវៈទាំងស្រុង÷ សំដៅទៅលើ [លក្ខខណ្ឌមួយដែល] អវយវៈពីរក្នុងចំណោមអវយវៈទាំងបី គឺរឹង ឬមិនអាចធ្វើចលនាដោយសេរីបាន។ អវយវៈ សំដៅទៅលើអវយវៈខាងលើទាំងអស់ រួមទាំងសន្លាក់ស្មាឬអវយវៈខាងក្រោមទាំងអស់ រួមទាំងសន្លាក់ត្រគាក។

(2) ការបាត់បង់ទាំងស្រុងនៃមុខងារសម្រាប់ការនិយាយ ឬការទំពារ និងការលេប÷ ការបាត់បង់ទាំងស្រុងនូវការនិយាយ សំដៅទៅលើភាពអសមត្ថភាពក្នុងការធ្វើឲ្យមានសម្លេងបីក្នុងចំណោមបួនប្រភេទនៃសម្លេង (រួមបញ្ចូលទាំង) ដើម្បីបញ្ចេញសំលេងបី (រួមមានបបូរមាត់ ធ្មេញ និងអណ្តាត ក្រអូមមាត់ និងបំពង់ក) ឬខ្សែសំលេងត្រូវបានកាត់ផ្តាច់ទាំងស្រុង ឬការរងរបួសខួរក្បាលដែលបណ្តាលឲ្យមានជំងឺពិបាកស្តាប់ ដោយសារតែមជ្ឈមណ្ឌលភាសាមានបញ្ហា។ ការបាត់ បង់ទាំងស្រុងនូវមុខងារទំពារ និងការលេប សំដៅទៅលើស្ថានភាពជំងឺរបស់រាងកាយមួយ ឬការធ្វើប្រតិបត្តិការខុស ដែលបណ្តាលមកពីហេតុផលផ្សេងៗក្រៅពីធ្មេញ ដែលធ្វើឲ្យអសមត្ថភាពក្នុងការទំពារ ឬលេប និងអសមត្ថភាពក្នុងការញ៉ាំ ឬលេបចំណីអាហារផ្សេងៗក្រៅពីវត្ថុរាវ។

(3) សកម្មភាពរស់នៅប្រចាំថ្ងៃជាមូលដ្ឋានចំនួនប្រាំមួយសំដៅលើ (១) ការស្លៀកពាក់÷ លទ្ធភាពក្នុងការស្លៀកពាក់ ឬដោះសំលៀកបំពាក់ចេញដោយខ្លួនឯង (២) ការធ្វើចលនា÷ ការធ្វើចលនាពីកន្លែងមួយទៅកាន់កន្លែងមួយទៀតដោយខ្លួនឯង (៣) អាកប្បកិរិយា÷ ការចូលសម្រាក/គេង ឬការក្រោកពីគេង ឬការជិះរទេះរុញដោយខ្លួនឯង (៤) ការបន្ទោបង់÷ ការគ្រប់គ្រងការបន្ទោបង់ដោយខ្លួនឯង (៥) ការញ៉ាំ÷ ការញ៉ាំអាហារពីក្នុងចានសម្លរ ឬចាន ឬដាក់អាហារចូលក្នុងមាត់ដោយខ្លួនឯង និង (៦) ការងូតទឹក÷ ការងូតទឹកដោយខ្លួនឯង។

(4) អចិន្ត្រៃយ៍ និងជារៀងរហូត÷ សំដៅទៅលើ [លក្ខខណ្ឌមួយដែល] គិតចាប់ពីកាលបរិច្ឆេទនៃការធ្វើរោគវិនិច្ឆ័យ ឬការកើតឡើងនូវឧបទ្ទវហេតុដោយចៃដន្យ ក្នុងរយៈពេល ១៨០ថ្ងៃនៃការព្យាបាល [ជំងឺ] នៅតែមិនអាចព្យាបាលបានតាមវិធីសាស្ត្រព្យាបាលជំងឺដែលមានស្រាប់។

**តារាងឧបសម្ព័ន្ធ ៤៖ “តារាងតម្លៃសាច់ប្រាក់រាល់ចុងឆ្នាំនីមួយៗនៃកិច្ចសន្យាធានារ៉ាប់រងនេះ”**

តារាងតម្លៃសាច់ប្រាក់សម្រាប់អ្នកត្រូវបានធានារ៉ាប់រង ភេទស្រី ដែលមានអាយុ 20ឆ្នាំ នៅពេលដាក់ពាក្យស្នើសុំទិញធានារ៉ាប់រង។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចុងឆ្នាំទី១: | 0.00 | ចុងឆ្នាំទី២: | 0.00 | ចុងឆ្នាំទី៣: | 453.10 | ចុងឆ្នាំទី៤: | 812.80 |
| ចុងឆ្នាំទី៥: | 1,185.60 | ចុងឆ្នាំទី៦: | 1,571.70 | ចុងឆ្នាំទី៧: | 1,971.60 | ចុងឆ្នាំទី៨: | 2,385.90 |
| ចុងឆ្នាំទី៩: | 2,814.70 | ចុងឆ្នាំទី១០: | 3,258.80 | ចុងឆ្នាំទី១១: | 3,717.60 | ចុងឆ្នាំទី១២: | 4,192.70 |
| ចុងឆ្នាំទី១៣: | 4,684.20 | ចុងឆ្នាំទី១៤: | 5,192.30 | ចុងឆ្នាំទី១៥: | 5,717.30 | ចុងឆ្នាំទី១៦: | 6,259.90 |
| ចុងឆ្នាំទី១៧: | 6,820.40 | ចុងឆ្នាំទី១៨: | 7,399.20 | ចុងឆ្នាំទី១៩: | 7,997.20 | ចុងឆ្នាំទី២០: | 8,614.80 |
| ចុងឆ្នាំទី២១: | 9,251.70 | ចុងឆ្នាំទី២២: | 9,910.20 | ចុងឆ្នាំទី២៣: | 10,590.50 | ចុងឆ្នាំទី២៤: | 11,293.60 |
| ចុងឆ្នាំទី២៥: | 12,020.20 | ចុងឆ្នាំទី២៦: | 12,771.40 | ចុងឆ្នាំទី២៧: | 13,548.30 | ចុងឆ្នាំទី២៨: | 14,352.30 |
| ចុងឆ្នាំទី២៩: | 15,185.10 | ចុងឆ្នាំទី៣០: | 16,048.60 | ចុងឆ្នាំទី៣១: | 16,484.40 | ចុងឆ្នាំទី៣២: | 16,932.80 |
| ចុងឆ្នាំទី៣៣: | 17,394.30 | ចុងឆ្នាំទី៣៤: | 17,869.60 | ចុងឆ្នាំទី៣៥: | 18,359.70 | ចុងឆ្នាំទី៣៦: | 18,865.30 |
| ចុងឆ្នាំទី៣៧: | 19,387.20 | ចុងឆ្នាំទី៣៨: | 19,925.10 | ចុងឆ្នាំទី៣៩: | 20,479.30 | ចុងឆ្នាំទី៤០: | 21,050.10 |
| ចុងឆ្នាំទី៤១: | 6,097.50 | ចុងឆ្នាំទី៤២: | 6,255.80 | ចុងឆ្នាំទី៤៣: | 6,417.80 | ចុងឆ្នាំទី៤៤: | 6,583.30 |
| ចុងឆ្នាំទី៤៥: | 6,752.40 | ចុងឆ្នាំទី៤៦: | 6,925.40 | ចុងឆ្នាំទី៤៧: | 7,102.60 | ចុងឆ្នាំទី៤៨: | 7,284.50 |
| ចុងឆ្នាំទី៤៩: | 7,471.60 | ចុងឆ្នាំទី៥០: | 7,664.10 | ចុងឆ្នាំទី៥១: | 7,862.20 | ចុងឆ្នាំទី៥២: | 8,066.20 |
| ចុងឆ្នាំទី៥៣: | 8,276.20 | ចុងឆ្នាំទី៥៤: | 8,492.70 | ចុងឆ្នាំទី៥៥: | 8,716.50 | ចុងឆ្នាំទី៥៦: | 8,948.80 |
| ចុងឆ្នាំទី៥៧: | 9,191.10 | ចុងឆ្នាំទី៥៨: | 9,445.50 | ចុងឆ្នាំទី៥៩: | 9,714.20 | ចុងឆ្នាំទី៦០: | 10,000.00 |



អាគារកាណាឌីយ៉ាជាន់ទី26 CDEF វិថីព្រះអង្គឌួងលេខ315 ក្រុងភ្នំពេញ 26th Floor CDEF Canadia Tower 315 Ang Doung Street Phnom Penh Tel: 023989218